ឧបសម្ព័ន្ធ ២៖ ការព្យាករហិរញ្ញវត្ថុតាមការចង្អុលបង្ហាញ ........ 23

ឧបសម្ព័ន្ធ ៣ - យុទ្ធសាស្ត្រអឺរ៉ុបរួម ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ សម្រាប់កម្ពុជា ឆ្នាំ ២០២១-២០២៧ – វិស័យអាទិភាព និងវិស័យទាក់ទងនឹងវិស័យ OECD DAC5 និង SDGs. ........ 25

# ១. ទិដ្ឋភាពទូទៅនៃកិច្ចសហប្រតិបត្តិការរបស់ដៃគូអឺរ៉ុបនៅកម្ពុជា

## ១.១ ស្ថានភាព និងមូលដ្ឋានគ្រឹះសម្រាប់ការធ្វើកម្មវិធីរួម

ដៃគូអឺរ៉ុបបានឯកភាពក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ជាមួយព្រះរាជាណាចក្រកម្ពុជា តាមរយៈការធ្វើកម្មវិធីរួម។ កិច្ចសហការនេះ **គឺឈរលើយុទ្ធសាស្ត្រអឺរ៉ុបរួម (JES)** ដែលជាឯកសារកម្មវិធីពហុឆ្នាំ បង្កើតឡើងរួមគ្នាដោយ ដៃគូអឺរ៉ុប ក្នុងការកំណត់ក្របខ័ណ្ឌភាពជាដៃគូរវាងអឺរ៉ុប និងប្រទេសកម្ពុជា។ គោលបំណងសំខាន់នៃការធ្វើកម្មវិធីរួម និងយុទ្ធសាស្ត្រអឺរ៉ុបរួមនេះ គឺដើម្បីលើកកម្ពស់សង្គតិភាពគោលនយោបាយអឺរ៉ុប បង្កើនកិត្តិសព្ទ និងការយល់ដឹងអំពីការប្តេជ្ញាចិត្តរួមរបស់អឺរ៉ុប និងធានាឱ្យមានលទ្ធផលកាន់តែប្រសើរឡើង ក្នុងកិច្ចសហប្រតិបត្តិការអឺរ៉ុប និងភាពជាដៃគូជាមួយប្រទេសកម្ពុជា។ យុទ្ធសាស្ត្រនេះ មានទស្សនៈវិស័យផ្តល់ការគាំទ្រប្រកបដោយប្រសិទ្ធភាព ដល់ដំណើរការអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលដឹកនាំដោយប្រទេសកម្ពុជា ដែលមានរួមបញ្ចូលអភិក្រមសិទ្ធិមនុស្ស សំដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការជំរុញឱ្យមានបរិយាបន្ន សមធម៌ សមភាព និងភាពធន់។ គុណតម្លៃប្រជាធិបតេយ្យ តម្លាភាព និងគណនេយ្យភាពទៅវិញទៅមក នឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អឺរ៉ុប ដែលអនុលោមតាមនិយាមភាពជាដៃគូសាកល។

យុទ្ធសាស្ត្រអឺរ៉ុបរួម ឆ្នាំ២០២១-២០២៧ មានគោលដៅធ្វើការជាមួយព្រះរាជាណាចក្រកម្ពុជា ដើម្បីការស្តារសេដ្ឋកិច្ច-សង្គម ប្រកបដោយបរិយាបន្ន ចីរភាព និងអព្យាក្រឹតអាកាសធាតុ ព្រមទាំងគាំទ្រដល់ការពន្លឿនកំណែទម្រង់ទាំងឡាយ ស្របតាមរបៀបវារៈអភិវឌ្ឍន៍ជាតិរបស់កម្ពុជា និងនិយាមនៅក្នុងទិដ្ឋភាពគោលនយោបាយជាច្រើន ដើម្បីបន្សុីជាមួយអាទិភាពជាយុទ្ធសាស្ត្រ និងគុណតម្លៃជាសាកលរបស់អឺរ៉ុប។ យុទ្ធសាស្ត្រនេះនឹងជំរុញការតភ្ជាប់ និងការធ្វើសមាហរណកម្មកម្ពុជានៅក្នុងអាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ ព្រមទាំងបង្កើនសក្តានុពលក្នុងការតភ្ជាប់ប្រទេសកម្ពុជាទៅនឹងជំនាញ និងស្តង់ដារអឺរ៉ុប ហើយទន្ទឹមនឹងនេះ យុទ្ធសាស្ត្រអឺរ៉ុបរួមក៏នឹងបង្កើតឱ្យមានកិច្ចសហការកាន់តែជិតស្និទ្ធ ជាមួយសង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នអប់រំផងដែរ។ ជាមួយនឹងវិធីសាស្ត្រនេះ យុទ្ធសាស្ត្រអឺរ៉ុបរួមក៏នឹងដោះស្រាយបញ្ហាប្រឈមដែលបណ្តាលមកពីការសម្រេចចិត្តដកដោយផ្នែកនៃប្រព័ន្ធអនុគ្រោះពន្ធ "អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ (EBA)" ផងដែរ។

គុណតម្លៃ និងគោលការណ៍រួម ដែលជាមូលដ្ឋានគ្រឹះគាំទ្រសកម្មភាពរបស់ដៃគូអឺរ៉ុបនៅប្រទេសកម្ពុជារួមមាន៖



## ១.២ យុត្តិកម្ម និងបរិបទ

ដៃគូអឺរ៉ុបបានធ្វើការជាមួយគ្នា តាមរយៈការធ្វើកម្មវិធីរួម (រួមបញ្ចូលទាំងការអនុវត្ត និងការវិភាគរួមគ្នា) ចាប់តាំងពី ឆ្នាំ២០១៤ ក្នុងភាពជាដៃគូជាមួយព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមលើកកម្ពស់ជីវិតប្រកបដោយសេចក្តីថ្លៃថ្នូរ សម្រាប់មនុស្សគ្រប់គ្នា។

សម្រាប់រយៈពេលពី ឆ្នាំ២០២១ ដល់ ឆ្នាំ២០២៧ យុទ្ធសាស្ត្រអឺរ៉ុបរួម ផ្តោតកិច្ចសហប្រតិបត្តិការទៅលើវិស័យណា ដែលមានភាពស្របគ្នារវាងអាទិភាព និងឧត្តមភាពប្រកួតប្រជែងរបស់អឺរ៉ុប ជាមួយនឹងអាទិភាពរបស់ប្រទេសកម្ពុជា និងស្របតាមទិសដៅកិច្ចសហប្រតិបត្តិការរបស់ភាពជាដៃគូយុទ្ធសាស្ត្រអឺរ៉ុប-អាស៊ាន។

### ក) អាទិភាពសាកល និងឧត្តមភាពប្រកួតប្រជែងរបស់សហភាពអឺរ៉ុប សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

យោងតាម មាត្រា២០៨ នៃសន្ធិសញ្ញាស្តីពីមុខងាររបស់សហភាពអឺរ៉ុប និងមាត្រា២១ (២) នៃសន្ធិសញ្ញាសហភាពអឺរ៉ុប គោលបំណងនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អឺរ៉ុប គឺដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថានប្រកបដោយចីរភាព នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដែលក្នុងនោះគោលដៅចម្បង គឺដើម្បីលុបបំបាត់ភាពក្រីក្រ។

កុងសង់ស៊ុសអឺរ៉ុបស្តីពីការអភិវឌ្ឍ ឆ្នាំ២០១៧ សង្កត់ធ្ងន់លើគោលដៅនេះ ដោយតម្រង់គោលនយោបាយអភិវឌ្ឍន៍របស់សហភាពអឺរ៉ុប ឱ្យស្របជាមួយរបៀបវារៈ ឆ្នាំ២០៣០ ហើយគូសបញ្ជាក់បន្ថែមលើប្រជាធិបតេយ្យ នីតិរដ្ឋ សិទ្ធិមនុស្ស និងគោលការណ៍សមភាព និងសាមគ្គីភាព ដែលជាបេះដូងនៃរបៀបវារៈ ឆ្នាំ២០៣០។

យោងលើកិច្ចព្រមព្រៀងបៃតងរបស់អឺរ៉ុប សហភាពអឺរ៉ុបបានដាក់ចេញនូវយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចបៃតងថ្មីរបស់ខ្លួន ជាមួយនឹងផែនទីបង្ហាញផ្លូវឆ្ពោះទៅកាន់អព្យាក្រឹតអាកាសធាតុនៅត្រឹមឆ្នាំ២០៥០ ដោយកំណត់សហភាពអឺរ៉ុបជាអ្នកនាំមុខគេក្នុងសកម្មភាពអាកាសធាតុ។ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់សហភាពអឺរ៉ុប អាចជាយន្តការមួយដើម្បីចូលរួមចំណែកក្នុងការការពារអាកាសធាតុ និងបរិស្ថាន (រួមទាំងថាមពលស្អាត) នៅក្រៅសហភាពអឺរ៉ុប និងដើម្បីគាំទ្រប្រទេសកំពុងអភិវឌ្ឍលើមាគ៌ាឆ្ពោះទៅរកការផ្លាស់ប្តូរអេកូឡូស៊ីសាកល។

### ខ) អាទិភាពអភិវឌ្ឍន៍របស់ព្រះរាជាណាចក្រកម្ពុជា

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាល ទី៤ (យុទ្ធសាស្ត្រចតុកោណ) តំណាងឱ្យចក្ខុវិស័យអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ឆ្នាំ២០១៩-២០២៣ និងមានទិសដៅជំរុញប្រទេសកម្ពុជាឱ្យឆ្ពោះទៅដល់គោលដៅ ប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹម ឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។ យុទ្ធសាស្ត្រចតុកោណ ដែលផ្តោតលើប្រធានបទរួមស្តីពីកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាព មានចំណុចស្នូលផ្អែកលើកំណែទម្រង់អភិបាលកិច្ច និងដាក់ចេញនូវគោលដៅអាទិភាពចំនួន ៤ (ជ្រុងរបស់ចតុកោណ)។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ដែលរួមបញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា គឺដើម្បីអនុវត្តរបៀបវារៈនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាល ទី៤ និងធ្វើការប៉ាន់ប្រមាណចំណាយបណ្តោះអាសន្ន ព្រមទាំងក្របខ័ណ្ឌពិនិត្យតាមដាន។ យុទ្ធសាស្ត្រចតុកោណរបស់កម្ពុជា គាំទ្រដល់សំណុំយុទ្ធសាស្ត្រ និងផែនការជាតិ (ភាគច្រើនគ្របដណ្តប់ដល់ ឆ្នាំ២០៣០) ដែលផ្តោតលើការប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ យុទ្ធសាស្ត្រចតុកោណបានកំណត់ថា ការផ្លាស់ប្តូរនេះ ទាមទារឱ្យមានការពង្រឹងស្ថាប័នសាធារណៈ និងសមត្ថភាពវិស័យសាធារណៈ ការគោរពសិទ្ធិមនុស្ស អភិបាលកិច្ច និងនីតិរដ្ឋ ការផ្លាស់ប្តូរចនាសម្ព័ន្ធ ការងារដែលមានគុណភាព សេវាសាធារណៈ សន្តិសុខប្រាក់ចំណូល (ពិសេសសម្រាប់ប្រជាជនស្ថិតក្នុងស្ថានភាពងាយរងគ្រោះ) ឧស្សាហកម្ម ៤.០ ការគ្រប់គ្រងធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រចតុកោណក៏ផ្តោតផងដែរលើប្រសិទ្ធភាព និងការសម្របសម្រួលតាមខ្សែដេក ។

កម្មវិធីតាមវិស័យ និងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ផ្តល់នូវធាតុចូលលម្អិតដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ធ្វើឱ្យផែនការនេះអាចបង្ហាញយ៉ាងលម្អិតពី ទិសដៅគោលនយោបាយកម្រិតខ្ពស់ ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ។ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូរបស់រាជរដ្ឋាភិបាល (DCPS) បង្ហាញពីការរៀបចំសម្រាប់ការសម្របសម្រួល និងការសន្ទនា ដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ក្នុងការអនុវត្តគោលការណ៍ប្រសិទ្ធភាពនៃការអភិវឌ្ឍរបស់យន្តការភាពជាដៃគូសាកល។

### គ) ភាពជាដៃគូយុទ្ធសាស្ត្រអឺរ៉ុប- អាស៊ាន

អាស៊ាន និងសហភាពអឺរ៉ុប បានបើកទំព័រថ្មីមួយនៅក្នុងទំនាក់ទំនងរបស់ខ្លួន ដោយបានក្លាយជាដៃគូយុទ្ធសាស្ត្រនៅ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២០។ កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន-សហភាពអឺរ៉ុប លើកទី២៣ បានសង្កត់ធ្ងន់ពីជំហររួមគ្នា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ លើការអនុវត្តរបៀបវារៈ ឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ និងក្របខ័ណ្ឌសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ កិច្ចប្រជុំនេះ បានទទួលស្គាល់ពីភាពចាំបាច់នៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយ ដើម្បីអភិរក្ស និងប្រើប្រាស់បេតិកភណ្ឌធម្មជាតិក្នុងតំបន់ឱ្យមានចីរភាព។ ទំនាក់ទំនងរវាងសហភាពអឺរ៉ុប និងអាស៊ាន គឺផ្អែកលើគុណតម្លៃ និងគោលការណ៍រួម ដែលមានជាអាទិ៍ របៀបរបបដែលផ្អែកលើច្បាប់ ពហុភាគីនិយម និងពាណិជ្ជកម្មសេរី និងយុត្តិធម៌។ វិស័យសំខាន់ៗនៃកិច្ចសហប្រតិបត្តិការអឺរ៉ុប-អាស៊ាន គឺកិច្ច

សហប្រតិបត្តិការសេដ្ឋកិច្ច ការអភិវឌ្ឍប្រកបដោយចីរភាព ការតភ្ជាប់ប្រកបដោយចីរភាព និងកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ ដែលក្នុងនោះកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អឺរ៉ុប ផ្តោតសំខាន់លើវិស័យ ៣ ដំបូង។

លើសពីនេះទៅទៀត ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) ដែលបានព្រមព្រៀងធ្វើឡើងក្នុង ឆ្នាំ២០២០ ផ្តល់នូវក្របខ័ណ្ឌក្នុងការពង្រឹងពាណិជ្ជកម្មក្នុងតំបន់ (និងក្រៅតំបន់)។ នៅក្នុងរយៈពេលមធ្យម កិច្ចព្រមព្រៀងនេះផ្តល់ឱកាសឱ្យដៃគូអឺរ៉ុប ជួយប្រទេសកម្ពុជាឱ្យសម្រេចបានកាន់តែប្រសើរឡើងនូវសមាហរណកម្មសេដ្ឋកិច្ច និងខ្សែចង្វាក់តម្លៃរបស់ខ្លួន នៅទូទាំងពិភពលោក និងនៅក្នុងតំបន់ ដោយអនុលោមជាពិសេសតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។

### ឃ) បញ្ហាប្រឈម និងកាលានុវត្តភាពនៃការអភិវឌ្ឍ ដែលនាំមកដោយជំងឺរាតត្បាតសាកល កូវីដ-១៩

ប្រទេសកម្ពុជាបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតនេះបានយ៉ាងល្អ ក្នុងអំឡុងពេលមួយឆ្នាំដំបូង។ ជំងឺរាតត្បាតនេះបង្កផលប៉ះពាល់ទូទៅលើសេដ្ឋកិច្ច-សង្គម ដោយបង្កឱ្យមានការធ្លាក់ចុះនូវអត្រាកំណើនសេដ្ឋកិច្ច ក៏ដូចជាបង្កើននូវភាពអត់ការងារធ្វើ។ វិស័យសំខាន់ៗ ដូចជា ទេសចរណ៍ និងបដិសណ្ឋារកិច្ច ក៏ដូចជាវិស័យកាត់ដេរសម្លៀកបំពាក់ បានរងផលប៉ះពាល់យ៉ាងខ្លាំង។ រដ្ឋាភិបាលកម្ពុជាបានអនុម័តវិធានការមួយចំនួន ដើម្បីទប់ទល់នឹងផលប៉ះពាល់សង្គម និងសេដ្ឋកិច្ច ដែលបង្កឡើងដោយជំងឺរាតត្បាតនេះ ដូចដែលបានកំណត់នៅក្នុងផែនការសកម្មភាពជាតិស្តីពី "ការត្រៀមរៀបចំ និងឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា"។ ទោះបីជាមិនទាន់ប្រាកដនៅឡើយថាតើពេលណាជំងឺកូវីដ-១៩ នឹងត្រូវបានបញ្ចប់ ក៏ជំងឺនេះទំនងនៅតែបន្តផលប៉ះពាល់ដល់សេដ្ឋកិច្ច និងចោទជាហានិភ័យបន្ថយល្បឿន ក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ ទន្ទឹមនឹងនេះ បញ្ហាប្រឈមថ្មីៗនៃការអភិវឌ្ឍ ដែលបង្កឡើងដោយជំងឺរាតត្បាតនេះ ក៏បានបង្កើតផងដែរនូវឱកាសសម្រាប់កិច្ចសហប្រតិបត្តិការដើម្បី "កសាងឡើងវិញឱ្យកាន់តែប្រសើរ"។ ឱកាសទាំងនេះត្រូវបានដៃគូអឺរ៉ុបធ្វើការពិចារណាជាពិសេស ក្នុងការតម្រង់ទិសសាជាថ្មីសម្រាប់កិច្ចសហប្រតិបត្តិការ ជាមួយព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅក្នុងក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមក្រុមអឺរ៉ុប (TEIs)។

## ១.៣. គោលបំណងរួម និងវិស័យអាទិភាព នៃយុទ្ធសាស្ត្រអឺរ៉ុបរួមសម្រាប់ព្រះរាជាណាចក្រកម្ពុជា

គោលបំណងរួមនៃយុទ្ធសាស្ត្រអឺរ៉ុបរួម ឆ្នាំ២០២១-២០២៧ គឺដើម្បីធ្វើការក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបន្តអនុវត្តរបៀបវារៈ ឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីគាំទ្រដល់ការតភ្ជាប់កម្ពុជាជាមួយអាស៊ាន និងបង្រួមគម្លាតអភិវឌ្ឍន៍ រវាងបណ្តាប្រទេសជាសមាជិកអាស៊ាន សំដៅធ្វើឱ្យ



ប្រសើរឡើងនូវសមាហរណកម្មក្នុងតំបន់ និងពិភពលោក។ ដៃគូអឺរ៉ុបនឹងរួមចំណែកកាត់បន្ថយភាពក្រីក្រ និងវិសមភាពនៅក្នុងប្រទេស តាមរយៈការជំរុញកំណើនសេដ្ឋកិច្ចបៃតង ប្រកបដោយចីរភាព និងបរិយាបន្ន ការបង្កើតការងារសមរម្យ ការអភិវឌ្ឍមនុស្ស ព្រមទាំងអភិបាលកិច្ចប្រកបដោយប្រជាធិបតេយ្យ តម្លាភាព និងគណនេយ្យភាពផងដែរ។ ដៃគូអឺរ៉ុបនឹងផ្តោតលើការពង្រឹងសមត្ថភាពស្ថាប័ននៅគ្រប់កម្រិតទាំងអស់ ការជំរុញឱ្យមានសង្គមស៊ីវិលដែលមានលក្ខណៈសកម្ម និងចម្រុះ និងលើកកម្ពស់អភិក្រមដែលផ្អែកលើលទ្ធផល និងអភិក្រមសិទ្ធិមនុស្ស ព្រមទាំងសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី នៅក្នុងប្រទេសកម្ពុជា។

ដើម្បីសម្រេចបានគោលបំណងរួមនេះ ដៃគូអឺរ៉ុបនឹងផ្តោតលើវិស័យអាទិភាពចំនួន ៦ ដែលមានសន្ទុះសម្រាប់កំណែទម្រង់ និងការសម្របតាមរបៀបវារៈអភិវឌ្ឍន៍របស់កម្ពុជា ដែលអាចបន្សីជាមួយអាទិភាព និងគុណតម្លៃអឺរ៉ុប ក៏ដូចជាតម្លៃបន្ថែមរបស់ដៃគូអឺរ៉ុបដែលបានកំណត់ជារួម។ វិស័យទាំង ៦ នេះ រួមមាន៖

១ **ពង្រឹងគណនេយ្យភាព** ប្រជាធិបតេយ្យ សុចរិតភាព និងប្រសិទ្ធភាពនៃ ប្រព័ន្ធនិងសេវាស្ថាប័នសាធារណៈរបស់កម្ពុជានៅគ្រប់លំដាប់ថ្នាក់ ("ផ្នែកផ្គត់ផ្គង់នៃអភិបាលកិច្ច") ដោយផ្តោតជាពិសេសលើកម្មវិធីកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ រួមទាំងអំពើពុករលួយ។

២ **ជំរុញឱ្យមានការចូលរួមតាមបែបប្រជាធិបតេយ្យ** ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ និងការគាំទ្រឱ្យមានបរិយាកាសអំណោយផល សម្រាប់សង្គមស៊ីវិលនៅកម្ពុជា ("ផ្នែកតម្រូវការនៃអភិបាលកិច្ច")។

៣ **គាំទ្រដល់សេវាកម្មដែលមានគុណភាព** ដែលអាចរកបាន និងដែលមានបរិយាបន្ន ដើម្បីពង្រឹងការអភិវឌ្ឍមនុស្ស សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ដែលសេវាកម្មនេះគ្របបណ្តប់ទាំងការអប់រំ ការអភិវឌ្ឍជំនាញ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ វិស័យសុខភាព អាហារូបត្ថម្ភ និងការគាំពារសង្គម ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសង្គម និងជនបទផងដែរ។

៤ **ពង្រឹងលទ្ធភាពប្រកួតប្រជែងរបស់កម្ពុជានៅលើទីផ្សារក្នុងតំបន់** និងពិភពលោក តាមរយៈការអភិវឌ្ឍពាណិជ្ជកម្ម និងវិស័យឯកជន ការបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច និងការផលិតប្រកបដោយចីរភាព ក៏ដូចជាការអនុវត្តគោលការណ៍ការងារសមរម្យ ស្របតាមស្តង់ដារអន្តរជាតិ។

៥ **ការអភិវឌ្ឍបៃតង ប្រកបដោយចីរភាព** រាប់បញ្ចូលទាំងការគ្រប់គ្រងធនធានធម្មជាតិ ការការពារ និងអភិរក្សបរិស្ថាន ការកាត់បន្ថយហានិភ័យបណ្តាលមកពីគ្រោះមហន្តរាយ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់ថាមពលបៃតង និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថាមពល ការអភិវឌ្ឍកសិកម្ម វារីវប្បកម្ម ជលផល និងព្រៃឈើប្រកបដោយចីរភាព និងការបោសសម្អាតមីននៅប្រទេសកម្ពុជា។

៦ **ការគាំទ្រយ៉ាងសកម្ម និងស្របគ្នា** សម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌របស់ប្រទេសកម្ពុជា ដោយផ្តោតជាពិសេសលើតំបន់អង្គរ និងតំបន់ផ្សេងទៀត។

ដៃគូអឺរ៉ុបនឹងអនុវត្តយុទ្ធសាស្ត្រនេះ ក្នុងអំឡុងពេលដែលបានកំណត់ តាមរយៈការបែងចែកការទទួលខុសត្រូវការងារ និងហិរញ្ញវត្ថុដែលបានចង្អុលបង្ហាញ ទៅតាមវិស័យ និងដៃគូនីមួយៗ។

បើធៀបនឹងយុទ្ធសាស្ត្រអឺរ៉ុបរួមមុន (ឆ្នាំ២០១៤-២០២០) យុទ្ធសាស្ត្រថ្មីនេះនៅតែបន្តផ្តោតលើកំណែទម្រង់អភិបាលកិច្ច ការអភិវឌ្ឍសង្គម និងការពង្រឹងសេដ្ឋកិច្ច ក៏ដូចជាការគាំទ្រដល់សមាហរណកម្មរបស់កម្ពុជានៅក្នុង និងក្រៅតំបន់ ប៉ុន្តែបន្ថែមការយកចិត្តទុកដាក់ខ្លាំងជាងមុនលើការពង្រឹងការស្តារឡើងវិញនូវ សេដ្ឋកិច្ច-សង្គម និងភាពធន់ ជាពិសេសទាក់ទងនឹងសុខភាព កំណើនសេដ្ឋកិច្ចបៃតង ការបង្កើតការងារសមរម្យ ជំនាញ ការគាំពារសង្គម និងជីវភាពរស់នៅ ដើម្បីឆ្លើយតបទៅនឹងជំងឺកូវីដ-១៩។

ការធ្វើរបៀបនេះ បានឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលផ្តោតលើសង្គម ក្នុងវដ្តនៃយុទ្ធសាស្ត្រទី១ ឆ្នាំ២០១៤-២០២០ ទៅជារបៀបវារៈ ឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលមានលក្ខណៈទូលំទូលាយជាងមុន និងបង្ហាញពីការសម្រេចតាមអាទិភាពសាកលរបស់អឺរ៉ុប រាប់ទាំងកិច្ចព្រមព្រៀងបៃតងផងដែរ។ វិធីសាស្ត្រនេះ ក៏រួមចំណែកក្នុងការសម្រេចគោលបំណង "មិនទុកចោលនរណាម្នាក់" នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលការណ៍ក្រោយកូវីដ-១៩ ដើម្បី "កសាងឡើងវិញឱ្យកាន់តែប្រសើរ" ដោយបង្ហាញពីតម្រូវការឱ្យមានការស្តារឡើងវិញដែលមានលក្ខណៈបៃតង ការទទួលយក និងសម្របគ្នាជាមួយនិយាម និងបទដ្ឋានអន្តរជាតិនានា នៅក្នុងប្រទេសកម្ពុជា និងនៅកម្រិតតំបន់។

គ្រប់វិស័យអាទិភាពទាំងអស់សុទ្ធតែមានវិធានការ ដើម្បីដោះស្រាយបញ្ហាប្រឈមជាលក្ខណៈប្រព័ន្ធ ជុំវិញសមត្ថភាព និងការសម្របសម្រួល ទាំងនៅក្នុងរាជរដ្ឋាភិបាល និងជាមួយដៃគូអភិវឌ្ឍន៍។ ដូចបានបញ្ជាក់ខាងលើ អាទិភាពពហុវិស័យ ដូចជាអភិក្រមសិទ្ធិមនុស្ស (ការមិនរើសអើង ការចូលរួម តម្លាភាព និងគណនេយ្យភាព) ចីរភាពអាកាសធាតុ និងបរិស្ថាន សមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងការចូលរួមរបស់យុវជន នឹងទ្រទ្រង់ដល់គ្រប់វិស័យអាទិភាពទាំងអស់។ យុទ្ធសាស្ត្រអឺរ៉ុបរួមក៏កំណត់ផងដែរនូវ ចំណុចចាប់ផ្តើមដើម្បីជំរុញឌីជីថលភាវូបនីយកម្ម និងជួយដល់ស្ថាប័នដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងការធានាភាពស៊ីចង្វាក់គ្នា ចីរភាពនៃដំណោះស្រាយផ្នែកបច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន និងការបន្សីជាមួយនិយាម និងស្តង់ដារអន្តរជាតិពាក់ព័ន្ធនានា ជាពិសេសទាក់ទងនឹងការការពារទិន្នន័យ។

# ២. ការគាំទ្ររបស់ដៃគូអឺរ៉ុប ក្នុងវិស័យអាទិភាព

វិស័យអាទិភាពទាំង ៦ ដែលបានបង្ហាញនៅក្នុងផ្នែកនេះពង្រឹងគ្នាទៅវិញទៅមក ហើយនៅក្នុងរូបភាពរួម កំណត់កម្មវិធីកិច្ចសហប្រតិបត្តិការដែលមានតុល្យភាព និងភាពស៊ីចង្វាក់គ្នា ដែលពាក់ព័ន្ធទៅនឹងអាទិភាពជាតិ និងស្របជាមួយអាទិភាព និងអភិក្រម "គោលនយោបាយជាចម្បង"។

## ២.១ វិស័យអាទិភាពទី ១៖ ពង្រឹងគណនេយ្យភាពប្រជាធិបតេយ្យ សុចរិតភាព និងប្រសិទ្ធភាពនៃប្រព័ន្ធនិងសេវាស្ថាប័នសាធារណៈរបស់កម្ពុជានៅគ្រប់លំដាប់ថ្នាក់ ("ផ្នែកផ្គត់ផ្គង់នៃអភិបាលកិច្ច") ដោយផ្តោតជាពិសេសលើកម្មវិធីកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ រួមទាំងអំពើពុករលួយ

ដៃគូអឺរ៉ុបនឹងគាំទ្រកម្មវិធី **កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)** ដើម្បីលើកកម្ពស់វិន័យសារពើពន្ធ បង្កើនប្រសិទ្ធភាព និងតម្លាភាពថវិកា និងគណនេយ្យភាព ក៏ដូចជាដើម្បីបង្កើនការប្រមូលផ្តុំធនធានក្នុងស្រុក កែលម្អការបែងចែកធនធានហិរញ្ញវត្ថុសម្រាប់ការផ្តល់សេវាដែលមានគុណភាពកាន់តែប្រសើរ ការចូលរួមរបស់ប្រជាពលរដ្ឋ និងការត្រួតពិនិត្យរបស់សភា។ ដៃគូអឺរ៉ុបនឹងគាំទ្រឱ្យមានការចូលរួមកាន់តែច្រើនពីក្រសួងពាក់ព័ន្ធនានា ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នេះ។ នៅក្នុងបរិបទនៃការអន្តរាគមន៍កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សហភាពអឺរ៉ុបអាចផ្តល់ការគាំទ្របន្ថែមដល់កំណែទម្រង់រដ្ឋបាលសាធារណៈ (PAR) ដើម្បីពង្រឹងទំនាក់ទំនងរវាងកំណែទម្រង់អភិបាលកិច្ចនានា។

**កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (SNDD)** នៅតែមានភាពជាប់ទាក់ទងខ្លាំងទៅនឹងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ជាពិសេស ដើម្បីការពារសិទ្ធិរបស់ជនដែលងាយរងគ្រោះបំផុត ក្នុងការទទួលបានសេវាសាធារណៈប្រកបដោយគុណភាព និងសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងមូលដ្ឋាន។ ដៃគូអឺរ៉ុបនឹងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិ លើកទី ២ ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ឆ្នាំ ២០២១-២០៣០) និងក្របខ័ណ្ឌចម្រុះសម្រាប់គណនេយ្យភាពសង្គម (ISAF)។ ការចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវាដែលផ្តោតលើពលរដ្ឋ ការលើកទឹកចិត្តឱ្យចូលរួម និងការចូលរួមរបស់ពលរដ្ឋ គណនេយ្យភាពសង្គម និងការអភិវឌ្ឍមូលដ្ឋានស្ថិតនៅចំណុចកណ្តាលនៃការគាំទ្រនេះ។

ដៃគូអឺរ៉ុបនឹងបន្តការពិភាក្សាគោលនយោបាយរបស់ខ្លួនជាមួយរដ្ឋាភិបាល ស្តីពីអភិបាលកិច្ចរួមបញ្ចូលទាំង **ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សផងដែរ។** ក្នុងបរិបទនៃយុទ្ធសាស្ត្រអឺរ៉ុបរួមនេះ ដៃគូអឺរ៉ុបនឹងពិចារណាប្រសិនបើអាចធ្វើទៅបាន ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ការកែលម្អនីតិរដ្ឋ រួមទាំងការធ្វើកំណែទម្រង់វិស័យយុត្តិធម៌ និងការអនុលោមតាមអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។ ការចូលរួមក្នុងអភិបាលកិច្ច ក៏នឹងរួមបញ្ចូលទាំងការធ្វើការជាមួយកម្ពុជា ដើម្បីកែលម្អបរិយាកាសពាណិជ្ជកម្ម និងធុរកិច្ច តាមរយៈការធ្វើឱ្យប្រសើរឡើងនូវតម្លាភាព ភាពដែលអាចព្យាករបាន និងភាពច្បាស់លាស់ នៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ កិច្ចសម្រួលពាណិជ្ជកម្ម និងការចូលទៅកាន់ទីផ្សារកាន់តែប្រសើរ ក៏ដូចជាការសម្របតាមឧត្តមានុវត្តន៍ និងស្តង់ដារអន្តរជាតិឱ្យបានកាន់តែល្អ។

ការកាត់បន្ថយអំពើពុករលួយ **មានសារៈសំខាន់** និងចាំបាច់ដើម្បីឆ្លើយតបនឹងការប្តេជ្ញាចិត្តនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាល ទី៤ សម្រាប់ "យុត្តិធម៌សង្គម និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមភាព" និងដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងភាពទាក់ទាញនៃការវិនិយោគ។ ដៃគូអឺរ៉ុបក៏នឹងលើកកម្ពស់ការសម្របសម្រួលអន្តរកំណែទម្រង់របស់រដ្ឋាភិបាល ដែលមានសារៈសំខាន់ ក្នុងការជំរុញកំណែទម្រង់អភិបាលកិច្ចនានា។

ទិន្នន័យ និងស្ថិតិ ដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំការអភិវឌ្ឍនៅប្រទេសកម្ពុជា។ ទាំងអស់នេះផ្តល់ភ័ស្តុតាងចាំបាច់ ដើម្បីបង្កើត និងតាមដានគោលនយោបាយអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ដើម្បីបង្ហាញថាតើកន្លែងណាដែលត្រូវការធនធានច្រើនបំផុត និងផ្តល់មធ្យោបាយ ដើម្បីតាមដានវឌ្ឍនភាព និងវាយតម្លៃលទ្ធផល និងគុណផលនៃគោលនយោបាយផ្សេងៗ។ ដូច្នេះដៃគូអឺរ៉ុបនឹងគាំទ្រដល់ប្រព័ន្ធស្ថិតិជាតិ ក្នុងទិដ្ឋភាពរួម ដើម្បីពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការសម្របសម្រួល និងឆ្លើយតបទៅនឹងតម្រូវការដែលកំពុងកើនឡើង សម្រាប់ព័ត៌មានស្ថិតិដែលមានគុណភាពខ្ពស់ បែងចែកទៅតាមភេទនិងអាយុ ទាន់ពេលវេលា និងអាចរកបាន ដែលចាំបាច់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភ័ស្តុតាង និងបង្កើនតម្លាភាព និងគណនេយ្យភាព។

## ២.២ វិស័យអាទិភាពទី ២៖ ជំរុញការចូលរួមបែបប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ និងគាំទ្របរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលនៅកម្ពុជា (“ផ្នែកតម្រូវការនៃអភិបាលកិច្ច”)

ដៃគូអឺរ៉ុបចាត់ទុកការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចល្អ ជាកត្តាសំខាន់បំផុតមួយក្នុងចំណោមកត្តាសំខាន់បំផុតផ្សេងៗទៀត ដែលគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាពនៅកម្ពុជា ហើយទទួលស្គាល់ថា ទំនាក់ទំនងរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល គឺជាទិដ្ឋភាពដ៏ចាំបាច់មួយនៃអភិបាលកិច្ចល្អ។

ដៃគូអឺរ៉ុបនឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលើកកម្ពស់ការចូលរួមបែបប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលនៅកម្ពុជា ក៏ដូចជាគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ។ ទាំងនេះមានសារៈសំខាន់ក្នុងការផ្តល់សិទ្ធិអំណាចដល់យុវជន (ស្ត្រី និងបុរស ក្មេងស្រី និងក្មេងប្រុស) ដើម្បីឱ្យរដ្ឋាភិបាលមានគណនេយ្យភាពនៅគ្រប់កម្រិត។

ក្នុងការលើកកម្ពស់ឱ្យមានបរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលនៅកម្ពុជា ដៃគូអឺរ៉ុបនឹងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព ភាពធន់ និងការចូលរួមរបស់សង្គមស៊ីវិល។ ការគាំទ្រនេះនឹងរួមបញ្ចូលទាំងសកម្មភាពដែលផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌច្បាប់សម្រាប់សង្គមស៊ីវិល សេរីភាពក្នុងការបង្កើតសមាគម ការជួបជុំ និងការបញ្ចេញមតិ ក៏ដូចជាការចូលរួមរបស់សង្គមស៊ីវិលក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងវាយតម្លៃថវិកា។ អង្គការសង្គមស៊ីវិលនៅកម្ពុជា នឹងបន្តទទួលបានអត្ថប្រយោជន៍ពីការគាំទ្រដែលមាននិរន្តរភាពរបស់អឺរ៉ុប ក្នុងការលើកកម្ពស់សិទ្ធិមនុស្ស នីតិរដ្ឋ ដំណើរការប្រជាធិបតេយ្យ និងដើម្បីរួមចំណែក ដល់សង្គមមួយដែលមានបរិយាបន្ន តម្លាភាព គណនេយ្យភាព និងចីរភាព។

ភាគីពាក់ព័ន្ធទាំងអស់ (សង្គមស៊ីវិល រួមទាំងអង្គការស្ត្រី វិស័យឯកជន សហជីព តំណាងរាស្ត្រ តំណាងរដ្ឋាភិបាលមូលដ្ឋាន) នឹងចូលរួមក្នុងកិច្ចសន្ទនាគោលនយោបាយ ក៏ដូចជាការពិគ្រោះយោបល់ និងការសម្របសម្រួលជាប្រចាំ ស្របតាមគោលការណ៍ប្រសិទ្ធភាពនៃការអភិវឌ្ឍភាពជាដៃគូសាកល។



ដៃគូអឺរ៉ុបមានការប្តេជ្ញាចិត្តខ្ពស់ចំពោះ **សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។** ដៃគូអឺរ៉ុបនឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ ដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សា និងការរើសអើងទាក់ទងនឹងយេនឌ័រ ការលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច សង្គម វប្បធម៌ នយោបាយ និងសិទ្ធិពលរដ្ឋរបស់ស្ត្រី។ ការប្តេជ្ញាចិត្តទាំងនេះត្រូវបានបកប្រែឱ្យទៅជាសកម្មភាពជាក់ស្តែង តាមរយៈផែនការសកម្មភាព យេនឌ័រ និងត្រូវបានរាយការណ៍រួមគ្នាដោយដៃគូអឺរ៉ុប។ ដៃគូអឺរ៉ុបទាំងអស់នៅកម្ពុជាបានចាត់តាំងជនបង្គោលផ្នែកយេនឌ័រ (GFP) មួយរូប។

ដៃគូអឺរ៉ុបនឹងបន្តធ្វើការជាមួយកម្ពុជា ដោយសហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្នុងការខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើងនូវ**ការគ្រប់គ្រងដីធ្លី** ដោយផ្តោតលើគោលនយោបាយផ្តល់កម្មសិទ្ធិដីសមូហភាព និងការតាំងទីលំនៅថ្មី។ ការគាំទ្រក៏នឹងផ្តោតឆ្ពោះទៅរកអង្គការសង្គមស៊ីវិល ដែលផ្តល់ជំនួយដល់សហគមន៍ដែលងាយរងគ្រោះបំផុត ក្នុងការការពារសិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួន បង្កើនការចូលរួម និងការទទួលបានព័ត៌មាន តម្លាភាព និងគណនេយ្យភាពជុំវិញការគ្រប់គ្រងដីធ្លី និងការគ្រប់គ្រងរបស់សហគមន៍លើធនធានធម្មជាតិ ដូចជាព្រៃឈើ និងទីតាំងនេសាទ។

នៅថ្នាក់តំបន់ ដៃគូអឺរ៉ុបគាំទ្រដល់កសិករខ្នាតតូច និងដល់អ្នកប្រើប្រាស់ធនធានព្រៃឈើក្នុងការទទួលបានសិទ្ធិ និងការគ្រប់គ្រងដែលមានការធានា និងមានសមភាព លើដីកសិកម្ម និងព្រៃឈើក្នុងតំបន់មេគង្គ។ ប្រទេសដែលពាក់ព័ន្ធមួយចំនួនបានចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់របស់ខ្លួនលើបញ្ហាច្បាប់ និងគោលនយោបាយស្តីពីអភិបាលកិច្ចដីធ្លី - ដែលនៅតែជាចំណុចស្នូលនៃបញ្ហាប្រឈមនៃការអភិវឌ្ឍក្នុងតំបន់។

## ២.៣. វិស័យអាទិភាពទី ៣៖ គាំទ្រដល់ការផ្តល់សេវាកម្មដែលមានគុណភាព ភាពអាចរកបាន និងដែលមាន បរិយាបន្ន ដើម្បីពង្រឹងការអភិវឌ្ឍធនធានមនុស្ស ដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ រួមបញ្ចូលការអប់រំ ការអភិវឌ្ឍជំនាញ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សុខភាព អាហារូបត្ថម្ភ និងការគាំពារសង្គម ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសង្គម និងជនបទជាដើម

ដៃគូអឺរ៉ុបនឹងធ្វើការក្នុងភាពជាដៃគូជាមួយកម្ពុជា ដើម្បីរួមចំណែកដល់ការផ្តល់សេវាដែលមានគុណភាព អាចរកបាន និងដែលមានបរិយាបន្ន ដើម្បីពង្រឹងការអភិវឌ្ឍធនធានមនុស្ស។ នៅពេលដែលធនធានមនុស្សរឹងមាំ នោះជាការរួមចំណែកឱ្យសង្គមស៊ីវិលរឹងមាំ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់។

**ការអប់រំ** - ដៃគូអឺរ៉ុបបានចូលរួមជាមួយប្រទេសកម្ពុជាក្នុង វិស័យអប់រំជាយូរមកហើយ។ ថ្មីៗនេះ ការគាំទ្រត្រូវបានសម្របទៅតាមកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការដោះស្រាយបញ្ហាប្រឈមនៃជំងឺកូវីដ-១៩។ ទាំងនេះរួមមានគំនិតផ្តួចផ្តើមការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត និងការសិក្សាពីចម្ងាយ និងធានាបាននូវការបើកសាលារៀនឡើងវិញដោយសុវត្ថិភាព។

ដៃគូអឺរ៉ុបនឹងបន្តចូលរួមជាមួយរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាព ភាពអាចរកបាន បរិយាបន្ន និងភាពធន់នៃប្រព័ន្ធអប់រំ ក៏ដូចជាជួយជំរុញអត្រាបញ្ចប់ការសិក្សាជាដើម។ ការអប់រំគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្ស ហើយចាំបាច់សម្រាប់ការអភិវឌ្ឍ និងការរីកចម្រើនជាបន្តបន្ទាប់របស់ប្រទេស។ គោលបំណងសំខាន់គឺ ដើម្បីបណ្តុះបណ្តាលកម្លាំងពលកម្មកម្ពុជានាពេលអនាគតជាមួយនឹងជំនាញដែលពាក់ព័ន្ធ និងសម្របការអប់រំទៅនឹងតម្រូវការទីផ្សារការងារ។

ផែនការយុទ្ធសាស្ត្រអប់រំ ២០១៩-២០២៣ ផ្តល់ក្របខ័ណ្ឌសម្រាប់ការគាំទ្រដៃគូអឺរ៉ុបដល់វិស័យនេះ។ បន្ទាប់ពីទទួលបានជោគជ័យនៃលទ្ធភាពចូលរៀនសាលាបឋមសិក្សាស្ទើរតែទាំងស្រុងក្រសួងអប់រំ យុវជន និងកីឡា នាពេលបច្ចុប្បន្នបាននិងកំពុងផ្តោតការយកចិត្តទុកដាក់បន្ថែមលើសមធម៌ និងគុណភាព ដើម្បីពង្រឹងលទ្ធផលសិក្សាដែលនៅមានកម្រិតទាបនៅឡើយ។

ដៃគូអឺរ៉ុបគាំទ្រអភិក្រមដែលបានអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តោតលើការកែទម្រង់រយៈពេលវែងប្រកបដោយចីរភាព ដើម្បីលើកកម្ពស់គុណភាព និងលទ្ធផលនៃការសិក្សានៅគ្រប់កម្រិតទាំងអស់។ ក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធនានា ដៃគូអឺរ៉ុបនឹងស្វះស្វែងផ្តោតការយកចិត្តទុកដាក់លើការអនុវត្តកំណែទម្រង់សំខាន់ៗ ដែលបានជ្រើសរើសនៅក្នុងវិស័យនេះ ដើម្បីបង្កើនឥទ្ធិពលជាអតិបរមានៃប្រតិបត្តិការរបស់ពួកគេ។

ដៃគូអឺរ៉ុបនឹងបន្តផ្តោតលើការអប់រំទាំងថ្នាក់មូលដ្ឋាន និងឧត្តមសិក្សា រាប់បញ្ចូលទាំងការអប់រំក្រៅប្រព័ន្ធផងដែរ និងកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការសម្រេចឱ្យបាននូវសមភាពយេនឌ័រ តាមរយៈការធ្វើការផ្លាស់ប្តូរខ្សែចង្វាក់ផ្នែកអប់រំ។ ខណៈការអប់រំថ្នាក់មូលដ្ឋាន រួមទាំងការអប់រំកុមារតូច បង្កើតមូលដ្ឋានគ្រឹះនៃការសិក្សាក៏ដោយ ការអប់រំថ្នាក់ឧត្តមសិក្សា និងការស្រាវជ្រាវ ក៏ត្រូវបានទទួលស្គាល់ថាមានសារៈសំខាន់ក្នុងការកសាងមូលធនមនុស្សសម្រាប់ការអភិវឌ្ឍអាជីព នវានុវត្តន៍ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចផងដែរ។ ប្រការនេះនឹងនាំឱ្យកម្ពុជាអនុលោមតាមនិយាមអាស៊ាន និងអន្តរជាតិ និងជួយបំពេញតម្រូវការទីផ្សារការងារ។

ក្នុងឆ្នាំ ២០២១-២០២៧ ដៃគូអឺរ៉ុបក៏នឹងបន្តផ្តល់មូលនិធិសម្រាប់ភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា និងអឺរ៉ុប រួមទាំងការកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រង ការស្រាវជ្រាវ និងការអប់រំព្រមទាំងការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជានិងសាស្ត្រាចារ្យថ្នាក់ឧត្តមសិក្សាផងដែរ។ ការសិក្សានៅសាកលវិទ្យាល័យឈានមុខគេនៅអឺរ៉ុប នឹងគាំទ្រដល់ការផ្សារភ្ជាប់ទំនាក់ទំនងរវាងការអប់រំថ្នាក់ឧត្តមសិក្សា និងការស្រាវជ្រាវវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងនវានុវត្តន៍។ លើសពីនេះទៅទៀតនឹងមានការខិតខំប្រឹងប្រែងរួមគ្នាដើម្បីធានាថា សិស្សនិស្សិតដែលមានទេពកោសល្យ និងមកពីគ្រួសារក្រីក្រលំបាក អាចមានឱកាសទទួលបាននូវកម្មវិធីអាហារូបករណ៍នៅថ្នាក់ឧត្តមសិក្សា។ ជាមួយនឹងគោលបំណងទាំងនេះ ភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា អឺរ៉ុប និងនៅបណ្តាប្រទេសជាសមាជិកអាស៊ានដទៃទៀត ដែលមានការអភិវឌ្ឍល្អរួចស្រាប់ហើយនោះ នឹងត្រូវបានធ្វើឱ្យប្រសើរឡើងបន្ថែមទៀត រួមទាំងតាមរយៈកម្មវិធី Erasmus ថ្មី ២០២១-២០២៧ ផងដែរ។

**ការអភិវឌ្ឍជំនាញ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** (TVET) ផ្តល់នូវចំណេះដឹង ជំនាញបច្ចេកទេស និងជំនាញទន់ជាច្រើន ក៏ដូចជាវិន័យដែលមិនអាចខ្វះបានសម្រាប់ការចូលរួមប្រកបដោយអត្ថន័យនៅក្នុងការងារ និងជីវិតរស់នៅ។ ដៃគូអឺរ៉ុបនឹងរួមចំណែកក្នុងការអភិវឌ្ឍជំនាញប្រកបដោយបរិយាបន្ន និងឆ្លើយតបនឹងយេនឌ័រ រួមទាំងជំនាញបំណិនជីវិត ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាព ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា ដែលជាអាទិភាពចម្បងក្នុងការងើបឡើងវិញនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា។ ដៃគូអឺរ៉ុបនឹងធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ និងក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាវិស័យឯកជន និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈទាំងរដ្ឋ និងឯកជនផងដែរ។ ពួកគេក៏នឹងចូលរួមក្នុងការអភិវឌ្ឍប្រព័ន្ធ និងគោលនយោបាយ ជំនួយបច្ចេកទេស ការអភិវឌ្ឍកម្មវិធី និងការស្រាវជ្រាវ។

វិស័យឯកជន គឺជាភ្នាក់ងារជំរុញកំណើនសេដ្ឋកិច្ច និងការងារនៃកម្លាំងពលកម្មដែលកំពុងកើនឡើងរបស់ប្រទេស។ ដូចនេះហើយ ដៃគូអឺរ៉ុបនឹងសហការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជនក្នុងការ រៀបចំ និងផ្តល់ការបណ្តុះបណ្តាលជំនាញ ក៏ដូចជាក្នុងការបង្កើតការងារសមរម្យ និងកន្លែងធ្វើការ។ ដៃគូអឺរ៉ុបនឹងលើកកម្ពស់ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ដែលមានសារៈសំខាន់សម្រាប់បង្កើនភាពពាក់ព័ន្ធ និងភាពជឿជាក់នៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅថ្នាក់ជាតិផងដែរ។



**សុខភាព** - ដៃគូអឺរ៉ុបទទួលស្គាល់ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះកំណែទម្រង់ក្នុងវិស័យសុខាភិបាល និងតម្រូវការក្នុងការធ្វើឱ្យកាន់តែប្រសើរឡើង នូវស្ថានភាពសុខភាព និងសុខុមាលភាពអ្នកជំងឺ។ ជាមួយនឹងការរីករាលដាលជំងឺកូវីដ-១៩ ការពង្រឹងប្រព័ន្ធសុខាភិបាលនៅកម្ពុជា ត្រូវបានពន្លឿន។ ដៃគូអឺរ៉ុបនឹងគាំទ្រដល់វិស័យសុខាភិបាល ដើម្បីធានាថា

ប្រជាជនទាំងអស់មានសិទ្ធិទទួលបានសុខុមាលភាពសង្គម និងអាចចូលរួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍនយោបាយ និងសេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ។

ដៃគូអឺរ៉ុបនឹងបន្តធ្វើការជាមួយក្រសួងសុខាភិបាល សម្រាប់ការអនុវត្តគម្រោងលើកកម្ពស់សមភាព និងគុណភាពសុខភាព (គម្រោង H-EQIP2) បន្តពីគម្រោង H-EQIP1 សម្រាប់នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ពួកគេនឹងជួយសម្របសម្រួលដល់ការរៀបចំប្រព័ន្ធទទួលស្គាល់គុណភាព និងថ្លៃសេវាសុខភាព។ លើសពីនេះទៀត ពួកគេនឹងគាំទ្រដល់ការបណ្តុះបណ្តាលមុនពេលចូលបម្រើការងារសម្រាប់បុគ្គលិកសុខាភិបាល ដើម្បីចូលរួមចំណែកក្នុងការផ្តល់សេវាសុខភាពដែលកាន់តែប្រសើរឡើង និងប្រកបដោយគុណភាព។

ក៏នឹងមានការគាំទ្រនៅក្នុងវិស័យសុខភាពមាតា និងសុខភាពបន្តពូជ សុខភាពកុមារ សុខភាពផ្លូវចិត្ត ជំងឺមិនឆ្លង ការស្រាវជ្រាវ និងការអប់រំថ្នាក់ឧត្តមសិក្សា (ជំនួយបច្ចេកទេស និងអាហារូបករណ៍) ផងដែរ ។

ដៃគូអឺរ៉ុបនៅតែបន្តការប្តេជ្ញាប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់នៅក្នុងប្រទេសកម្ពុជា តាមរយៈការវិនិយោគរបស់ពួកគេនៅក្នុងមូលនិធិសាកល និងជំនួយបច្ចេកទេសបន្ថែម និងគម្រោងមួយចំនួនទៀត។

**អាហារូបត្ថម្ភរួមមានសន្តិសុខស្បៀង និងសុវត្ថិភាពស្បៀងអាហារ** គឺជាផ្នែកសំខាន់នៃវិស័យសុខាភិបាល។ ដៃគូអឺរ៉ុបនឹងចូលរួមក្នុងកម្មវិធីអាហារូបត្ថម្ភតាមរយៈអភិក្រមពហុវិស័យ ដើម្បីឆ្លើយតបចំពោះបុព្វហេតុចម្បងនៃកង្វះអាហារូបត្ថម្ភ ជាពិសេសចំពោះស្ត្រី និងកុមារតូចៗ។



**កិច្ចគាំពារសង្គម** - ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមដែលកំពុងរីបឡើងវិញនៅតែជាអាទិភាព។ ដៃគូអឺរ៉ុបនឹងបន្តគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តក្របខ័ណ្ឌគោលនយោបាយគាំពារសង្គមថ្នាក់ជាតិ ទាំងសសរស្តម្ភនៃជំនួយសង្គម និងសសរស្តម្ភនៃសន្តិសុខសង្គម ក្នុងគោលបំណងធានាការការពារទូលំទូលាយដល់ពលរដ្ឋកម្ពុជាពេញមួយជីវិតរបស់ពួកគាត់។

នៅក្នុងបរិបទនៃវិបត្តិជំងឺកូវីដ-១៩ ដៃគូអឺរ៉ុបក៏នឹងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តប្រព័ន្ធគាំពារសង្គមដែលរួមបញ្ចូលគ្នា ឆ្លើយតបទាន់ពេលទៅភាពអាសន្ន ប្រកបដោយចីរភាព ដែលស្របតាមគោលបំណងនៃក្របខ័ណ្ឌដែលបានលើកឡើងខាងលើ។

ពួកគេក៏នឹងគាំទ្រផងដែរដល់ការអនុវត្ត "ផែនការសកម្មភាពជាតិរបស់កម្ពុជា៖ ការរៀបចំ និងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩" ដែលទាមទារឱ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធជាច្រើន ទាំងនៅក្នុងវិស័យសុខាភិបាល និងមិនមែនសុខាភិបាល។

តម្រូវការ និងឱកាសដើម្បីគាំទ្រក្របខ័ណ្ឌរួមសម្រាប់កិច្ចគាំពារសង្គមរបស់ពលករចំណាកស្រុកនៅក្នុងតំបន់អាស៊ាន នឹងត្រូវបានត្រួតពិនិត្យតាមដាន។

**ហេដ្ឋារចនាសម្ព័ន្ធសង្គម និងជនបទ** - ក្នុងភាពជាដៃគូរបស់ខ្លួនជាមួយកម្ពុជា ដៃគូអឺរ៉ុបនឹងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យសេដ្ឋកិច្ច និងសង្គម។

ដើម្បីសម្រេចគោលដៅនេះ ដៃគូអឺរ៉ុបនឹងចូលរួមចំណែកដល់ការអភិវឌ្ឍជនបទ និងទីក្រុងប្រកបដោយចីរភាព និងលទ្ធភាពទទួលបានអគ្គិសនី ទឹកស្អាត និងអនាម័យ ការគ្រប់គ្រងកាកសំណល់សំរាម (រួមទាំងការគ្រប់គ្រងទឹកកខ្វក់) ទីផ្សារជនបទ និងផ្លូវតាមទីជនបទ (រួមទាំងការថែទាំផ្លូវ វិធានការគាំទ្រហេដ្ឋារចនាសម្ព័ន្ធ ការស្តារផ្លូវថ្នល់ដែលធន់នឹងអាកាសធាតុ សុវត្ថិភាពចរាចរណ៍ផ្លូវគោក) ក៏ដូចជាផែនការនាវាចរណ៍តាមផ្លូវទឹកក្នុងស្រុកជាដើម។ ការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ និងប្រកបដោយចីរភាពនឹងត្រូវបានផ្តល់អាទិភាព និងកាន់តែត្រូវបានផ្តោតទៅលើការធានាបាននូវលក្ខណៈបរិយាបន្ននៃនគរូបនីយកម្ម រួមទាំងទិដ្ឋភាពយេនឌ័រ និងអភិក្រមសិទ្ធិមនុស្សផងដែរ។

ដៃគូអឺរ៉ុបនឹងជំរុញ និងគាំទ្រដល់ការតភ្ជាប់ទំនាក់ទំនងជនបទ ទីប្រជុំជន និងក្នុងតំបន់ឱ្យកាន់តែប្រសើរឡើងដោយផ្តោតខ្លាំងលើភាពធន់នឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

ការគាំទ្រដល់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្រសួងវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាកម្មទឹក និងអនាម័យទីប្រជុំជនក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានានឹងត្រូវបន្ត។ ជំនួយបច្ចេកទេសនឹងត្រូវបានផ្តល់ជូនសម្រាប់ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់ដែលមិនប៉ះពាល់ដល់បរិស្ថាន។

## ២.៤. វិស័យអាទិភាពទី ៤៖ បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងទីផ្សារក្នុងតំបន់ និងសាកលតាមរយៈការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិស័យឯកជន បង្កលក្ខណៈងាយស្រួលដល់បរិយាកាសធុរកិច្ច និងផលិតកម្មប្រកបដោយចីរភាព ក៏ដូចជាការអនុវត្តការងារសមរម្យស្របតាមស្តង់ដារអន្តរជាតិ

ដៃគូអឺរ៉ុបនឹងរួមចំណែកក្នុងផលិតភាពសេដ្ឋកិច្ចរបស់កម្ពុជា ការធ្វើពិពិធកម្ម និងភាពប្រកួតប្រជែង ក៏ដូចជាការតភ្ជាប់ទៅកាន់ពិភពលោក និងតំបន់របស់កម្ពុជា។ ដៃគូអឺរ៉ុបនឹងគាំទ្រដល់ការធ្វើសមាហរណកម្មរបស់កម្ពុជាក្នុងតំបន់អាស៊ាន និងមហាអនុតំបន់មេគង្គ ដោយបន្ថយគម្លាតអភិវឌ្ឍន៍ជាមួយបណ្តាប្រទេសអាស៊ានផ្សេងទៀត តាមរយៈការតភ្ជាប់ទំនាក់ទំនងកាន់តែប្រសើរឡើង ភាពប្រកួតប្រជែង ការធ្វើសមាហរណកម្មទីផ្សារក្នុងតំបន់ និងពិភពលោក និងខ្សែចង្វាក់តម្លៃ ជំនួយទាក់ទងនឹងពាណិជ្ជកម្ម បច្ចេកវិទ្យាបៃតង ស្តង់ដារអន្តរជាតិ ការអភិវឌ្ឍវិស័យឯកជន និងការបង្កលក្ខណៈងាយស្រួលដល់បរិយាកាសធុរកិច្ច។ ដៃគូអឺរ៉ុបក៏នឹងលើកកម្ពស់ផលិតកម្មប្រកបដោយចីរភាព និងជំរុញលក្ខខណ្ឌការងារ និងសិទ្ធិការងារ ស្របតាមអនុសញ្ញាអន្តរជាតិ និងតម្រូវការផ្នែកទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន រាប់បញ្ចូលទាំងផលប៉ះពាល់ដែលអាចមាននៃពាណិជ្ជកម្ម និងខ្សែចង្វាក់តម្លៃលើសិទ្ធិដីធ្លីផងដែរ។ វិស័យទាំងនេះកាន់តែមានសារសំខាន់ខ្លាំងឡើងថែមទៀតនៅប្រទេសកម្ពុជា បន្ទាប់ពីផលប៉ះពាល់នៃជំងឺកូវីដ១៩លើសេដ្ឋកិច្ច និងសង្គម។

**ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិស័យឯកជន** - តម្រូវការចាំបាច់ជាមុនសម្រាប់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងទំនើបភាវូបនីយកម្មរួមមាន ការជំរុញផលិតភាព ភាពប្រកួតប្រជែង ប្រសិទ្ធភាព និងនវានុវត្តន៍ ការបង្កើនលទ្ធភាពចូលទៅកាន់ទីផ្សារ វិធានការសម្របសម្រួលពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស គោលនយោបាយឧស្សាហកម្មទំនើប និងការអភិវឌ្ឍវិស័យឯកជន។ លើសពីនេះទៅទៀត បរិយាកាសច្បាប់ល្អអាចព្យាករបាន និងប្រកបដោយយុត្តិធម៌សម្រាប់ធុរកិច្ច និងការវិនិយោគ គឺជាបុរេលក្ខខណ្ឌសម្រាប់វិស័យឯកជនដែលរីកចម្រើន និងរឹងមាំដែលបង្កើតការងារ និងរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច។ វិស័យឯកជនរបស់កម្ពុជា ជាពិសេសសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម ត្រូវការការគាំទ្រយ៉ាងច្រើនដើម្បីប្រកួតប្រជែង ចូលទីផ្សារ និងធ្វើសមាហរណកម្មទៅក្នុងខ្សែចង្វាក់តម្លៃតំបន់ និងពិភពលោក។

កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីលើកកម្ពស់ការចូលទីផ្សាររបស់ខ្លួន តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយចំនួនជាមួយប្រទេសទីបី រួមទាំងនៅកម្រិតអាស៊ានផងដែរ។ ទោះយ៉ាងនេះក្តី ពាណិជ្ជកម្មក្នុងតំបន់នៅមានកម្រិតនៅឡើយ ដោយមានតែប្រមាណមួយភាគប្រាំនៃការនាំចេញប៉ុណ្ណោះដែលត្រូវបាននាំទៅកាន់ទីផ្សារអាស៊ាន។ ផ្ទុយទៅវិញ ការងារដោយផ្ទាល់រាប់សិបពាន់កន្លែង ជាពិសេសក្នុងវិស័យវាយនភណ្ឌ ត្រូវបានបង្កើតឡើងតាមរយៈការរៀបចំកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មឯកតោភាគីជាមួយបណ្តាប្រទេសលោកខាងលិច ដែលរួមចំណែកក្នុងការយកប្រជាជនជាច្រើនចេញពីភាពក្រីក្រ។ ដោយពិនិត្យឃើញថា វិស័យវាយនភ័ណ្ឌមានទំនាក់ទំនងជាមួយនឹងឱកាសការងារ ការអប់រំ បណ្តុះបណ្តាលបច្ចេកវិទ្យា និងវិជ្ជាជីវៈ ផលិតកម្មដែលមិនប៉ះពាល់ដល់បរិស្ថាន និងស្តង់ដារការងារ ដៃគូអឺរ៉ុបនឹងបន្តយកចិត្តទុកដាក់ជាពិសេសទៅលើការអភិវឌ្ឍវិស័យនេះឱ្យបានល្អប្រសើរ។ កម្ពុជាកំពុងចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសមួយចំនួនដើម្បីរក្សាកំណើនសេដ្ឋកិច្ច និងបង្កើតការងារតាមរយៈការលើកកម្ពស់ការធ្វើពិពិធកម្ម និងការចូលទៅកាន់ទីផ្សារ និងដើម្បីបន្ថយការពឹងផ្អែកលើការអនុគ្រោះពាណិជ្ជកម្មឯកតោភាគី។ ដៃគូអឺរ៉ុបនឹងសង្កត់ធ្ងន់លើការប្រកាន់ខ្ជាប់នូវស្តង់ដារអន្តរជាតិដែលពាក់ព័ន្ធ និងដំណើរការនៃកិច្ចខិតខំប្រឹងប្រែងដ៏ត្រឹមត្រូវ ដែលផ្តោតលើគោលការណ៍របស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស (រាប់បញ្ចូលទាំងបញ្ហាបរិស្ថាន សិទ្ធមនុស្សដែលអាចមាន ក៏ដូចជាសមភាពយេនឌ័រផងដែរ) ដែលជាផ្នែកមួយនៃការលើកកម្ពស់សមាហរណកម្មកម្ពុជាក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។

ស្របតាមការប្តេជ្ញាចិត្ត និងកាតព្វកិច្ចរបស់កម្ពុជាចំពោះអង្គការពាណិជ្ជកម្មពិភពលោក ដៃគូអឺរ៉ុបនឹងផ្តល់នូវជំនាញដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម លើកកម្ពស់ការចូលទៅកាន់ទីផ្សារ និងពង្រីកការតភ្ជាប់ទំនាក់ទំនងរវាងកម្ពុជា និងដៃគូអាស៊ាន។ ដៃគូអឺរ៉ុបនឹងផ្តោតសំខាន់លើការអនុវត្តកិច្ចព្រមព្រៀងសម្របសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងការប្តេជ្ញាចិត្ត នៅក្នុងផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន ក៏ដូចជាកំណែទម្រង់បទប្បញ្ញត្តិនានា ដើម្បីលើកកម្ពស់បរិយាកាសធុរកិច្ច និងសេវាកម្មហិរញ្ញវត្ថុ រួមទាំងសេវាកម្មដែលជះឥទ្ធិពលដល់ចំណាត់ថ្នាក់តំបន់របស់កម្ពុជាក្នុងការស្ទង់មតិប្រចាំឆ្នាំស្តីពីការធ្វើធុរកិច្ចផងដែរ។ កម្ពុជាបានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសដោយជោគជ័យ តាមរយៈការផ្លាស់ប្តូរទីតាំងផលិតកម្មដែលមានតម្លៃទាប និងរបបពន្ធដែលអំណោយផល។ ការបង្កើនភាពប្រកួតប្រជែង ការធ្វើពិពិធកម្មទីផ្សារ និងផលិតផល ក៏ដូចជាការធ្វើសមាហរណកម្មខ្សែចង្វាក់តម្លៃឧស្សាហកម្ម និងក្របខ័ណ្ឌបទប្បញ្ញត្តិដែលអាចព្យាករបាន គឺជាគន្លឹះដើម្បីទាក់ទាញការវិនិយោគបន្ថែម អនុញ្ញាតឱ្យក្រុមហ៊ុនក្នុងស្រុកពង្រីក និងបង្កើតការងារ។

ដើម្បីជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យកាន់តែទូលំទូលាយ ការជំរុញការនាំចេញ និងសមាហរណកម្មតំបន់ ដៃគូអឺរ៉ុបចាប់អារម្មណ៍ជាពិសេសក្នុងការគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនូវខ្សែចង្វាក់តម្លៃកសិឧស្សាហកម្មប្រកបដោយចីរភាព តាមរបៀបដែលមិនអនុគ្រោះដល់ការរំលោភបំពានយកដីធ្លី ការចងក្រងជាបណ្តាញផលិតករខ្នាតតូច និងការបង្កើតឱកាសការងារ។ ការផ្តល់លទ្ធភាពដល់វិស័យឯកជន (ជាពិសេសសហគ្រាសធុនតូច និងមធ្យម និងម្ចាស់ដីតូចៗ) ទទួលបានផលប្រយោជន៍ពេញលេញពីឱកាសក្នុងតំបន់ ក៏ដូចជាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានស្រាប់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្មី កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសទីបីក៏នឹងត្រូវបានគាំទ្រផងដែរ។ នៅក្នុងបរិបទនៃការអភិវឌ្ឍជនបទ ការទទួលយក និងការអនុវត្តមុខងារដោយឯករាជ្យក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដោយអាជ្ញាធរថ្នាក់ក្រោមជាតិនឹងត្រូវបានលើកទឹកចិត្ត ដែលនឹងរួមចំណែកដល់ការអនុវត្តទិដ្ឋភាពនៃកំណែទម្រង់វិមជ្ឈការ។

ការគាំទ្របន្ថែមរបស់អឺរ៉ុបក្នុងវិស័យពាក់ព័ន្ធដទៃទៀត ដូចជាកំណែទម្រង់ពន្ធ កសិកម្ម ជលផល ថាមពល និងការអភិវឌ្ឍជំនាញ ក៏មានតួនាទីសំខាន់ក្នុងការអភិវឌ្ឍវិស័យឯកជន និងការបង្កើនផលិតភាពការងារផងដែរ។ ដៃគូអឺរ៉ុបធ្វើការយ៉ាងជិតស្និទ្ធជាមួយសភាពាណិជ្ជកម្មអឺរ៉ុប (Eurocham) ដើម្បីចូលរួមប្រកបដោយលក្ខណៈស្ថាបនាជាមួយសមភាគីជាតិ ដើម្បីបរិយាកាសអាជីវកម្មរួមកាន់តែប្រសើរឡើង ក៏ដូចជាការលើកកម្ពស់តម្លៃ និងផលប្រយោជន៍អឺរ៉ុប រួមទាំងលក្ខខណ្ឌការងារ និងការផ្លាស់ប្តូរថាមពលស្អាត។

**ផលិតកម្មប្រកបដោយចីរភាព និងការងារសមរម្យ** - ដៃគូអឺរ៉ុបនឹងបន្តការគាំទ្រ និងលើកកម្ពស់ការអនុវត្តសិទ្ធិ និងលក្ខខណ្ឌការងារជាមូលដ្ឋាន រួមទាំងការទទួលបានសំណងស្របច្បាប់ជាដើម។ រួមជាមួយផលិតផលអឺរ៉ុប ដៃគូអឺរ៉ុបក៏នឹងបន្តគាំទ្រដល់ការកែលម្អស្តង់ដារសង្គម និងបរិស្ថានក្នុងវិស័យនាំចេញផងដែរ (ជាពិសេសវាយនភណ្ឌ) ។ ពួកគេនឹងបន្តផ្តោតលើការអភិវឌ្ឍ និងការពង្រឹងផលិតកម្មប្រកបដោយចីរភាព ដោយគាំទ្រដល់ការកែលម្អខ្សែចង្វាក់តម្លៃកសិកម្ម និងឧស្សាហកម្ម ការលើកកម្ពស់ សេដ្ឋកិច្ចមូលដ្ឋានក្នុងតំបន់ឱ្យបានកាន់តែល្អប្រសើរ ការគ្រប់គ្រងសំណល់/សេដ្ឋកិច្ចវិលជុំ និងការអភិវឌ្ឍសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម (MSMEs)។ ទំនាក់ទំនងរវាងការអភិវឌ្ឍជំនាញ និងឱកាសការងារសមរម្យនឹងត្រូវបានយកចិត្តទុកដាក់ជាពិសេស។

ដៃគូអឺរ៉ុបនឹងបន្តគាំទ្រដល់វឌ្ឍនភាពស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ ក្នុងបរិបទដែលមានកង្វះកម្មករជំនាញដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ដៃគូអឺរ៉ុបនឹងគាំទ្រគំនិតផ្តួចផ្តើមដែលអាចធ្វើឱ្យយុវជនមានលទ្ធភាពទទួលបានការអប់រំ ជំនាញ និងការងារប្រកបដោយគុណភាព ទន្ទឹមនឹងនោះ លើកកម្ពស់លក្ខខណ្ឌការងារប្រកបដោយភាពត្រឹមត្រូវ និងសមរម្យ ស្របតាមស្តង់ដាររបស់អង្គការពលកម្មអន្តរជាតិ។ ដៃគូអឺរ៉ុបនឹងជំរុញកិច្ចសន្ទនាសង្គមដែលប្រសើរឡើងនៅលើទីផ្សារការងារ និងភាពជាដៃគូរវាងរដ្ឋាភិបាល វិស័យឯកជន សហជីព និងសង្គមស៊ីវិល ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសាកលដែលកម្ពុជាបានចុះហត្ថលេខា។

**សេវាកម្មហិរញ្ញវត្ថុ** - ដៃគូអឺរ៉ុបនឹងគាំទ្រភាពធន់នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បន្ទាប់ពីមានវិបត្តិនៃការរាតត្បាតកូវីដ-១៩ និងរួមចំណែកក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុប្រកបដោយភាពទទួលខុសត្រូវ និងចីរភាពនៅក្នុងប្រទេស។ ដៃគូអឺរ៉ុបនឹងផ្តល់ការគាំទ្រដល់ប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុកដើម្បីអភិវឌ្ឍអភិក្រមមួយប្រកបដោយចីរភាព និងសម្របសមត្ថភាពក្នុងគោលដៅបម្រើដល់សហគ្រាសខ្នាតតូច រួមទាំងសហគ្រាសដែលដឹកនាំដោយស្ត្រីផងដែរ ជាពិសេសនៅតាមតំបន់ជនបទ។

## ២.៥. វិស័យអាទិភាពទី ៥៖ ការអភិវឌ្ឍបៃតងប្រកបដោយចីរភាពរួមមាន ការគ្រប់គ្រងធនធានធម្មជាតិ ការការពារ និងអភិរក្សបរិស្ថាន ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ផ្សព្វផ្សាយអំពីថាមពលបៃតង ប្រសិទ្ធភាពថាមពល ការអភិវឌ្ឍប្រកបដោយចីរភាពលើវិស័យកសិកម្ម វារីវប្បកម្ម ជលផល ព្រៃឈើ និងការបោសសម្អាតមីននៅក្នុងប្រទេសកម្ពុជា

ដៃគូអឺរ៉ុបនឹងចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងសមត្ថភាពផលិតកម្មប្រកបដោយនវានុវត្តន៍បៃតង និងប្រកបដោយចីរភាព។ ពួកគេនឹងសង្កត់ធ្ងន់លើការគ្រប់គ្រងធានធម្មជាតិ ប្រកបដោយចីរភាព និងបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ភាពធន់នឹងការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវចម្រុះ ទន្ទឹមនឹងការជំរុញការអភិវឌ្ឍខ្សែចង្វាក់តម្លៃឧស្សាហកម្មប្រកបដោយនវានុវត្តន៍ ដែលមានតម្លៃសមរម្យ និងចីរភាព ហេដ្ឋារចនាសម្ព័ន្ធ និងថាមពលបៃតងដែលរួមចំណែកដល់ការផ្សារភ្ជាប់ទំនាក់ទំនង កំណើនសេដ្ឋកិច្ចបៃតង និងការបង្កើតឲ្យមានការងារសមរម្យជាដើម។



**កសិកម្ម វារីវប្បកម្ម ជលផល និងព្រៃឈើ** - ដៃគូអឺរ៉ុបនឹងធ្វើការជាមួយកម្ពុជា ដើម្បីបង្កើនផលិតភាព ការធ្វើពិពិធកម្ម និងគុណភាពសម្រាប់កំណើនសេដ្ឋកិច្ចរបស់ប្រទេស ជីវភាពរស់នៅ និងការងារប្រកបដោយចីរភាពក៏ដូចជាការអភិវឌ្ឍជនបទប្រកបដោយសមធម៌។

កសិកម្មប្រកបដោយចីរភាព និងកសិ-ពាណិជ្ជកម្មដោយផ្តោតជាពិសេសលើបច្ចេកវិទ្យាបៃតង (រួមទាំងថាមពលបៃតង ជាពិសេសពន្លឺព្រះអាទិត្យ) ការធ្វើឌីជីថលនីយកម្ម និងតម្លៃបន្ថែម នឹងជួយជំរុញកំណើនសេដ្ឋកិច្ច ការងារបៃតង ទន្ទឹមនឹងការលើកកម្ពស់ភាពធន់ទៅនឹងអាកាសធាតុ ព្រមទាំងបរិស្ថានប្រកបដោយចីរភាព។ ដៃគូអឺរ៉ុបនឹងគាំទ្រខ្សែចង្វាក់តម្លៃកសិកម្មប្រកបដោយចីរភាព នៅក្នុងវិស័យផ្សេងៗគ្នា រួមមានវារីវប្បកម្ម សាកវប្បកម្ម និងផលិតផលសម្គាល់ភូមិសាស្ត្រ (ម្រេចកំពត ស្ករត្នោតកំពង់ស្ពឺ។ល។) ការពិចារណាលើការរំពឹងទុករបស់អ្នកប្រើប្រាស់ ក៏ដូចជាការកំណត់ការកាប់បំផ្លាញព្រៃឈើ និងការរេចរិលបរិស្ថាន។ សំខាន់ កិច្ចសហប្រតិបត្តិការអឺរ៉ុបនឹងគាំទ្រដល់ការស្តារ និងធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្ររបស់ប្រទេស ព្រមទាំងពង្រឹងក្របខ័ណ្ឌអភិបាលកិច្ចទឹក និងការវិនិយោគលើយន្តការគាំពារសង្គមជាដើម។ ការលើកកម្ពស់ប្រសិទ្ធភាពទឹក និងការគ្រប់គ្រងទីជម្រាលការស្តារតំបន់ទេសភាព វិធីសាស្ត្រកសិរុក្ខកម្ម និងកសិ-អេកូឡូស៊ី ការ

ធ្វើពិពិធកម្មដំណាំ និង/ ឬក៏ កសិកម្មឆ្លាតវៃតាមអាកាសធាតុ នឹងត្រូវបានរួមបញ្ចូល និងបង្កប់នៅក្នុងអភិក្រមគ្រប់គ្រងទេសភាព ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ និងការរេចរឹលធនធាន។ ដោយសារវិស័យកសិកម្មគឺជាកត្តាជំរុញដ៏សំខាន់នៃការកាប់ព្រៃឈើ និងការរំលោភដីធ្លី ការវិនិយោគលើវិស័យកសិកម្មរបស់អឺរ៉ុបនឹងត្រូវបានផ្សារភ្ជាប់ទៅនឹងកិច្ចគាំពារសង្គម បរិស្ថាន មហិច្ឆតាអភិរក្ស និងការការពារដោយត្រួតពិនិត្យលើសុក្រិតភាព។

វិស័យជលផល និងវារីវប្បកម្ម រួមចំណែកដល់កំណើនសេដ្ឋកិច្ច ក្នុងការបង្កើតឱកាសការងារ និងជាប្រភពអាហារូបត្ថម្ភមានតម្លៃសមរម្យ។ ការគាំទ្ររបស់អឺរ៉ុបនឹងផ្តោតលើវិស័យជលផល ទាំងទឹកសាប និងសមុទ្រ ការគ្រប់គ្រងរួមគ្នា ការលើកកម្ពស់ជីវភាពរស់នៅ ការការពារដីសើមនៅតំបន់ទន្លេសាប តំបន់មេគង្គរ៉ាមសាខាងលើ ក៏ដូចជាសហគមន៍នេសាទ ខ្សែចង្វាក់តម្លៃជលផល និងការធ្វើទីផ្សារ។ ការធ្វើឲ្យប្រសើរឡើង នូវការអនុវត្តក្នុងការគ្រប់គ្រងនឹងចូលរួមចំណែកកាត់បន្ថយការធ្វើអាជីវកម្មធនធានជលផលហួសប្រមាណ។ ការងារលើវិស័យជលផលក្នុងសមុទ្រក៏នឹងរួមបញ្ចូលការគាំទ្រដល់ដំណើរការរបស់ IUU (ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត) ហើយពឹងផ្អែកលើគំនិតផ្តួចផ្តើមក្នុងតំបន់ ឧទាហរណ៍ការគាំទ្រស្ថាប័នជលផលអាស៊ីអាគ្នេយ៍ ក៏ដូចជាជលផលអាស៊ាន និងកិច្ចសន្ទនា (IUU)។

វិស័យវារីវប្បកម្មដែលកំពុងរីកចម្រើននឹងត្រូវបានគាំទ្រដោយប្រព័ន្ធវប្បកម្មខ្នាតតូច និងពាក់កណ្តាលអតិផលទឹកសាប កន្លែងភ្ញាស់កូន និងថ្នាលបណ្តុះជាដើម។ វិស័យនេះមានសក្តានុពលក្នុងការរួមចំណែកដល់ការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញដូចជាការបង្កើតឱកាសការងារ និងឱកាសអាជីវកម្ម។ វាក៏មានសក្តានុពលផងដែរក្នុងការជំនួសការនាំចូលត្រី ហើយក៏រួមចំណែកយ៉ាងសំខាន់ដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភជាតិ។ កិច្ចសហការជាមួយវិស័យឯកជននឹងត្រូវបានដឹកនាំដោយយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីវប្បកម្មជាតិ (NADS) និងផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍវារីវប្បកម្មនៅកម្ពុជា។

ដៃគូអឺរ៉ុបបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការចូលរួមចំណែកដល់ការការពារ និងកែលម្អព្រៃឈើធម្មជាតិដែលមានស្រាប់ជាពិសេសព្រៃឈើចម្បងរបស់ខ្លួន បង្កើនគម្របព្រៃដោយចីរភាព និងមានជីវចម្រុះខ្ពស់នៅទូទាំងពិភពលោក រាប់បញ្ចូលការគាំទ្រដល់សហគមន៍ព្រៃឈើសម្រាប់ផលិតផលថ្មី។

ដោយសារៈសំខាន់នៃទឹកជំនន់ប្រចាំឆ្នាំ ចំពោះទំនាបកណ្តាលរបស់ប្រទេសកម្ពុជា សម្រាប់វិស័យកសិកម្ម និងជលផល ដែលផ្តល់ជីវភាពរស់នៅ និងស្បៀងសម្រាប់ប្រជាជនកម្ពុជារាប់លាននាក់ ការគាំទ្រនឹងត្រូវបានផ្តល់ដល់កម្ពុជាដែលជាផ្នែកមួយនៃតំបន់អាងទន្លេមេគង្គក្រោម ដោយសារដៃគូអឺរ៉ុបគាំទ្រគណៈកម្មការទន្លេមេគង្គ (MRC)។

ដៃគូអឺរ៉ុបគាំទ្រដល់ការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ចព្រៃឈើ (FLEGT) ដែលមានគោលបំណងដោះស្រាយបញ្ហានៃការកាប់ឈើខុសច្បាប់ ជំរុញការធ្វើពាណិជ្ជកម្មផលិតផលឈើស្របច្បាប់ និងរួមចំណែកដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។ កម្មវិធីរបស់ពួកគេក៏នឹងលើកកម្ពស់ក្នុងការប្រកាន់ខ្ជាប់ទៅនឹងស្តង់ដារបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ផងដែរ។

ដៃគូអឺរ៉ុប ដោយសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល សង្គមស៊ីវិល និងភាគីនានាក្នុងវិស័យឯកជន ក៏នឹងផ្តោតលើសហគមន៍ជនបទ ដើម្បីជួយធានាដល់ការទទួលបានធនធានព្រៃឈើ បង្កើនប្រាក់ចំណូល និងសន្តិសុខស្បៀងតាមរយៈការពង្រឹងការអនុវត្តផលិតកម្ម ទន្ទឹមនឹងនោះ ក៏មានការជំរុញកិច្ចសន្ទនាសាធារណៈស្តីពីការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពផងដែរ។

**ការគ្រប់គ្រងធនធានធម្មជាតិ ការការពារ និងការអភិរក្សបរិស្ថាន** ដៃគូអឺរ៉ុបនឹងចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការការពារ ការគ្រប់គ្រងធនធានធម្មជាតិ និងធនធានវប្បធម៌របស់ខ្លួនប្រកបដោយចីរភាព។ ដើម្បីធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចបន្តទៅមុខ រួមទាំងការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា វាគឺជារឿងចាំបាច់ណាស់ក្នុងការដាក់ការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាពឱ្យស្ថិតនៅជួរមុខនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់កម្ពុជា។ ក្នុងនោះមានវិធានការដោះស្រាយការគ្រប់គ្រងធនធានជលផលទឹកសាប និងសមុទ្រ ការកាប់បំផ្លាញព្រៃឈើ ការសឹករេចរឹលនៃប្រព័ន្ធអេកូឡូស៊ី និងការបាត់បង់ជីវចម្រុះ ការជួញដូរសត្វព្រៃ ការគ្រប់គ្រងតំបន់ការពារ ការគោរពសិទ្ធិដីធ្លី ក៏ដូចជាចីរភាពនៃផលិតកម្មអនុផលព្រៃឈើ។

ដៃគូអឺរ៉ុបនឹងបន្តធ្វើការជាមួយកម្ពុជាលើកិច្ចការពារ និងអភិរក្សបរិស្ថាន តាមរយៈសកម្មភាពដែលផ្តោតលើការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ការត្រួតពិនិត្យ និងការយកចិត្តទុកដាក់លើបរិស្ថាន (រួមមានព្រៃឈើ ធនធានទឹក ជលផល) តាមរយៈការអនុវត្តអភិក្រមរួមជាមួយ សហគមន៍ និងជនជាតិភាគតិចដែលរស់នៅក្នុងតំបន់ពាក់ព័ន្ធ។ ការគ្រប់គ្រងទេសភាពប្រកបដោយចីរភាពនឹងត្រូវបានគាំទ្រនៅជុំវិញតំបន់បឹងទន្លេសាប និងអាចមានតំបន់ទេសភាពសំខាន់ៗផ្សេងទៀត។ តាមទស្សនៈតំបន់ ការខិតខំបន្ថែមត្រូវបានធ្វើឡើងសម្រាប់ការអភិរក្ស និងកំណើនសេដ្ឋកិច្ចបៃតងនៅក្នុងតំបន់ជីវចម្រុះឥណ្ឌូ-ភូមា (ប្រទេសកម្ពុជា ឡាវ និងភូមា)។

**ការបោសសម្អាតមីន៖** ការគាំទ្ររបស់ដៃគូអឺរ៉ុប ស្របតាមយុទ្ធសាស្ត្រជាតិកំចាត់មីន ឆ្នាំ ២០១៨ -២០២៥ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា គោលដៅទី១៨ (ការបោសសម្អាតមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម) មានគោលបំណងរួមចំណែកដល់កម្ពុជាគ្មានគ្រាប់មីន ដែលការគំរាមកំហែងនៃសំណល់ជាតិផ្ទុះនៃសង្គ្រាម ត្រូវបានកាត់បន្ថយជាអតិបរមា ហើយការអភិវឌ្ឍមនុស្ស និងសង្គម សេដ្ឋកិច្ចកើតឡើងដោយសុវត្ថិភាព។ ការគាំទ្ររបស់អឺរ៉ុបក្នុង

ការបោសសម្អាតមីន គឺផ្តោតលើការបង្កើនជីវភាពរស់នៅ ព្រោះដីដែលបានឈូសឆាយបានផ្តល់នូវឱកាសសម្រាប់ការធ្វើកសិកម្ម និងផលិតកម្មផ្សេងៗ។

**ការប្រែប្រួលអាកាសធាតុ៖** ដៃគូអឺរ៉ុបនឹងធ្វើការជាមួយកម្ពុជា ដើម្បីបំពេញលក្ខខណ្ឌតម្រូវរបស់ខ្លួនចំពោះអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុគឺជាអាទិភាពទៅវិញទៅមក ទាំងដៃគូអឺរ៉ុប និងកម្ពុជាដើម្បីធ្វើការរួមគ្នាជួយសម្រេចឱ្យបាននូវការចូលរួមចំណែករបស់ជាតិ(NDC) កម្រិតបំភាយដែលបានកំណត់របស់កម្ពុជា និងផ្សព្វផ្សាយការអនុវត្ត ថ្នាក់ជាតិនៃក្របខ័ណ្ឌសេនដាយក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

កិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអឺរ៉ុប នឹងបន្តគាំទ្រដល់សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) កម្មវិធីហិរញ្ញវត្ថុអាកាសធាតុ និងតាមរយៈសកម្មភាពផ្សេងទៀត ដែលការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នឹងត្រូវបានបញ្ជ្រាបឧទាហរណ៍ ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សបរិស្ថាន ការបាត់បង់ជីវចម្រុះ ព្រៃឈើ នេសាទ (រួមទាំងវារីវប្បកម្ម) កសិកម្មប្រកបដោយចីរភាព ក៏ដូចជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាដើម។

ដៃគូអឺរ៉ុបក៏នឹងអនុវត្តគំនិតផ្តួចផ្តើមក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាលដោយផ្សព្វផ្សាយការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការខិតខំជួយដល់ប្រជាជនកម្ពុជា ជាពិសេសការដោះស្រាយអំពីភាពប៉ះពាល់ដល់អ្នកដែលអាស្រ័យផលធនធានធម្មជាតិ។ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នឹងត្រូវបានផ្សព្វផ្សាយដោយគំនិតផ្តួចផ្តើមទាក់ទងនឹងការផ្គត់ផ្គង់ទឹកស្អាត ការការពារប្រភពទឹក ការគ្រប់គ្រងទឹកកខ្វក់ ការប្រើប្រាស់ធនធានធម្មជាតិ និងធនធានរ៉ែប្រកបដោយចីរភាព។

**ថាមពលបៃតង និង ប្រសិទ្ធភាពថាមពល** - យុទ្ធសាស្ត្រអឺរ៉ុបរួមផ្តល់អាទិភាពលើការលើកកម្ពស់វិស័យថាមពលដែលអាចរកបាន និងមានតម្លៃសមរម្យ ដោយសង្កត់ធ្ងន់លើប្រសិទ្ធភាពថាមពល និងការប្រើប្រាស់ឱ្យបានកាន់តែប្រសើរនូវថាមពលកកើតឡើងវិញ។ ដៃគូអឺរ៉ុបនឹងបន្តកិច្ចសន្ទនាជាមួយរដ្ឋាភិបាលលើបញ្ហានេះ ចំពេលមានការប្រកាសរបស់អាជ្ញាធរក្នុងឆ្នាំ ២០២០ និង ២០២១ ឱ្យបង្កើនប្រសិទ្ធភាពនៃ ការប្រើប្រាស់ធ្យូងថ្ម និងឧស្ម័ន ដែលនឹងកាត់បន្ថយចំណែកនៃថាមពលកកើតឡើងវិញក្នុងការផលិតថាមពល។ ដៃគូអឺរ៉ុបនឹងត្រៀមខ្លួនធ្វើការជាមួយកម្ពុជា ដោយគាំទ្រថាមពលស្អាត ផ្អែកលើការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះថាមពលកកើតឡើងវិញ កម្រិតកាបូនទាប និងការអនុវត្តដែលប្រើថាមពលតិច។ វារួមបញ្ចូលទាំងការវិនិយោគនៅក្នុងបណ្តាញអគ្គិសនី ដែលប្រើប្រាស់ថាមពលតិច ហើយទំនើប និងការវិនិយោគក្នុងការបង្កើតបណ្តាញអគ្គិសនីដែលមានលក្ខណៈបត់បែន និងរួចជាស្រេច មានសមាមាត្រខ្ពស់នៃថាមពលកកើតឡើងវិញដែលមិនមានភាពទៀងទាត់ (ជាពិសេសថាមពលព្រះអាទិត្យ) ឧទាហរណ៍៖ តាមរយៈការរក្សាទុកថាមពល និងការគ្រប់គ្រងអគ្គិសនីឆ្លាតវៃ។ កិច្ចសហការជាមួយវិស័យឯកជនជាពិសេសឧស្សាហកម្មនាំចេញនឹងបន្តលើកកម្ពស់ប្រសិទ្ធភាពថាមពល និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដោយផ្សារភ្ជាប់ជាមួយការយកចិត្តទុកដាក់ផ្នែកបរិស្ថាន។

ដៃគូអឺរ៉ុប និងក្រុមហ៊ុននានាត្រៀមខ្លួនក្នុងការចែករំលែកបច្ចេកវិទ្យាបៃតង និងជំនាញ។ សៀវភៅ មគ្គុទេសចេញផ្សាយប្រចាំឆ្នាំ ២០១៩ របស់សភាពាណិជ្ជកម្មអឺរ៉ុបក៏មានការណែនាំមួយចំនួនសម្រាប់វិស័យពាណិជ្ជកម្ម និងការវិនិយោគក្នុងអាជីវកម្មបៃតង ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងហិរញ្ញប្បទានបៃតងផងដែរ។

## ២.៦. វិស័យអាទិភាពទី ៦៖ ការគាំទ្រយ៉ាងសកម្ម និងប្រកបដោយការសម្របសម្រួលសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌របស់កម្ពុជាដោយផ្តោតជាពិសេសលើ (តែមិនកំណត់ត្រឹម) តំបន់អង្គរ

កិច្ចខិតខំប្រឹងប្រែងអភិរក្សត្រូវអនុវត្តស្មើគ្នា ចំពោះបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជា។ ដៃគូអឺរ៉ុបនឹងបន្តដឹកនាំកិច្ចខិតខំប្រឹងប្រែងអន្តរជាតិ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងស្តារ អភិរក្ស និងលើកកម្ពស់តំបន់បេតិកភណ្ឌវប្បធម៌ពិភពលោករបស់កម្ពុជា រួមទាំងការចូលរួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្រាវជ្រាវ និងការកសាងសមត្ថភាពអ្នកជំនាញកម្ពុជានៅក្នុងវិស័យនេះផងដែរ។

## ២.៧ #TEAMEUROPE គំនិតផ្តួចផ្តើមក្រុមអឺរ៉ុប

គំនិតផ្តួចផ្តើមក្រុមអឺរ៉ុប (TEIs) គឺជាសកម្មភាពសម្របសម្រួលជាក់លាក់ និងបែបសមូហភាព ដោយសហភាពអឺរ៉ុប រដ្ឋជាសមាជិក និងទីភ្នាក់ងារអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុរបស់រដ្ឋទាំងនោះ។ គំនិតផ្តួចផ្តើមទាំងនេះត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់គំនិតផ្តួចផ្តើមសំខាន់ដែលមានមហិច្ឆតារបស់អឺរ៉ុប នៅក្នុងប្រទេសដៃគូ ដោយបង្កើតលទ្ធផលដែលមានការផ្លាស់ប្តូរជាអតិបរិមា។ នៅប្រទេសកម្ពុជា ក្រុមអឺរ៉ុបបានកំណត់រួចហើយនូវវិស័យសម្រាប់កិច្ចសហប្រតិបត្តិការចំនួនពីរ ដែលបានធ្វើសមកាលកម្ម និងពង្រឹងគ្នាទៅវិញទៅមក គឺ "ទេសភាព ព្រៃឈើ និងកសិកម្មប្រកបដោយចីរភាព" និងវិស័យមួយទៀតគឺ "ថាមពល និងខ្សែចង្វាក់តម្លៃឧស្សាហកម្មបៃតង"។ ទាំងនេះគឺពាក់ព័ន្ធក្នុងការអនុវត្តយុទ្ធសាស្ត្ររួមរបស់អឺរ៉ុបក្នុងវិស័យអាទិភាពចំនួន ៦ ហើយគាំទ្រដល់ការប្តេជ្ញាចិត្តរបស់សហភាពអឺរ៉ុប កម្ពុជា និងអាស៊ាន ដើម្បី "កសាងឱ្យកាន់តែប្រសើរឡើងវិញ" នៅក្នុងបរិបទក្រោយកូវីដ-១៩ ដោយលើកកម្ពស់កំណើនសេដ្ឋកិច្ចបៃតង ការងារ និងភាពធន់។

# ៣. វិធានការបន្ថែម

## ៣.១ ការចូលរួមជាមួយសង្គមស៊ីវិល

សង្គមស៊ីវិលដែលមានថាមវន្ត និងក្រុមអង្គការសង្គមស៊ីវិលដើរតួនាទីជា "ផ្នែកតម្រូវការ" នៃសមីការគណនេយ្យភាព។ អង្គការសង្គមស៊ីវិល ជាពិសេសក្រុមដែលធ្វើការផ្នែកសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ បង្ហាញការព្រួយបារម្ភកាន់តែខ្លាំងឡើងចំពោះបញ្ហាប្រឈមដែលពួកគេជួបប្រទះ ក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន។ ការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបាន ប្រែក្លាយទៅជាឧបសគ្គក្នុងការចុះបញ្ជី និងរៀបចំព្រឹត្តិការណ៍នានា ខណៈលក្ខខណ្ឌតម្រូវនៃរបាយការណ៍ អាចជាបន្ទុកធ្ងន់ធ្ងរសម្រាប់ពួកគេ។

ការចូលរួមរបស់ក្រុមអឺរ៉ុបជាមួយសង្គមស៊ីវិល មានគោលបំណងជំរុញបរិយាកាសអំណោយផលឱ្យកាន់តែប្រសើរ ជាពិសេសតាមរយៈការគាំទ្រដល់ការពន្លឿនការធ្វើកំណែទម្រង់ និងការផ្តល់សេវាកម្ម។ ដោយផ្អែកលើនិន្នាការវិជ្ជមាននានា ក្រុមអឺរ៉ុបនឹងបង្កើនចំណុចចាប់ផ្តើមនៅក្នុងគ្រប់វិស័យអាទិភាពទាំងអស់ ហើយនឹងបន្តចូលរួមដោយផ្ទាល់ ក្នុងកិច្ចសន្ទនាភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល វិស័យសិក្សាធិការ និងវិស័យឯកជន នៅលើវិស័យអាទិភាពទាំង ៦ នេះ។

## ៣.២ សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

ដៃគូអឺរ៉ុបនឹងរួមបញ្ចូលវិមាត្រយេនឌ័រក្នុងការអនុវត្តយុទ្ធសាស្ត្រអឺរ៉ុបរួម ដោយលើកកម្ពស់សមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងក្មេងស្រី និងការលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ការប្តេជ្ញាចិត្តនេះស្របនឹងផែនការសកម្មភាពសាកល លើកទី៣ របស់សហគមន៍អឺរ៉ុប ស្តីពីសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (GAP III, ២០២១-២០២៥) ដែលមានបំណងទប់ស្កាត់ការកើនឡើងនៃវិសមភាព ក្នុងបរិបទលំបាក ដែលបង្កឡើងដោយវិបត្តិសុខភាពសាធារណៈ និង សេដ្ឋកិច្ច-សង្គម នៃជំងឺកូវីដ-១៩ និងដើម្បីពន្លឿនវឌ្ឍនភាពលើសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ដែលជាទិដ្ឋភាពសំខាន់នៃការកសាងឡើងវិញឱ្យកាន់តែប្រសើរ។

ផែនការ GAP III សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការធ្វើការរួមគ្នាជាមួយរដ្ឋជាសមាជិកសហភាពអឺរ៉ុប និងដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូទាំងអស់ រួមទាំងសង្គមស៊ីវិល ជាពិសេស អង្គការ និងចលនាស្ត្រី និងយុវជន។

# ៤. រយៈពេលនៃយុទ្ធសាស្ត្រអឺរ៉ុបរួម និងជម្រើសសម្រាប់ការរួមបញ្ចូលគ្នា

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់កម្ពុជា នឹងបញ្ចប់នៅ ឆ្នាំ២០២៣។ ទោះយ៉ាងណាក៏ដោយ រយៈពេលកន្លងមក រាជរដ្ឋាភិបាលបានផ្សារភ្ជាប់យ៉ាងច្បាស់នូវកំណែទម្រង់ និងផែនការតាមវិស័យរបស់ខ្លួនទៅនឹងសេចក្តីប្រាថ្នាក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹម ឆ្នាំ២០៣០ ក៏ដូចជា ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ដូច្នេះ រយៈពេលអនុវត្តយុទ្ធសាស្ត្រអឺរ៉ុបរួម ឆ្នាំ២០២១-២០២៧ នេះ នឹងបង្កើតឱ្យមានការបន្សីជាថាមវន្ត ខណៈដែលអាទិភាពគោលនយោបាយជាតិមានការវិវឌ្ឍ ស្របតាមរបៀបវារៈ ឆ្នាំ២០៣០។ ការវាយតម្លៃពាក់កណ្តាលអាណត្តិក្នុង ឆ្នាំ២០២៤ លើយុទ្ធសាស្ត្រអឺរ៉ុបរួម នឹងផ្តល់ឱកាសសម្រាប់កិច្ចសន្ទនាជាមួយរាជរដ្ឋាភិបាល នៅចំពេលដែលរដ្ឋាភិបាលនឹងកំពុងរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ បន្ទាប់ទៀត (២០២៤-២០២៨)។

# ឧបសម្ព័ន្ធ ១៖ ក្របខ័ណ្ឌលទ្ធផលរួម

## ក្របខណ្ឌលទ្ធផល

រចនាសម្ព័ន្ធនៃក្របខ័ណ្ឌលទ្ធផល ត្រូវបានតម្រឹមឲ្យស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី៤ (RS-IV) របស់រាជរដ្ឋាភិបាលកម្ពុជា។ លទ្ធផលនៃក្របខ័ណ្ឌ និងសូចនាករលទ្ធផលដែលពាក់ព័ន្ធផ្អែកលើសូចនាករតាមដានរួមរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (JMIs) និងSDGs កម្ពុជា (CSDGs) ដែលមានស្រាប់។ តាមភាពចាំបាច់ លទ្ធផល និងសូចនាករបន្ថែមត្រូវបានកំណត់ដោយប្រើគំនិតផ្តួចផ្តើមរបស់អឺរ៉ុបដែលមានស្រាប់។

**គោលដៅរួម៖** ដើម្បីធ្វើការក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយដើម្បីគាំទ្រដល់ការតភ្ជាប់កម្ពុជាជាមួយអាស៊ាន និងបង្រួមគម្លាតអភិវឌ្ឍន៍រវាងបណ្តាប្រទេសជាសមាជិកអាស៊ាន សំដៅធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្មក្នុងតំបន់ និងពិភពលោក។ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងវិសមភាពក្នុងប្រទេស តាមរយៈការជំរុញកំណើនសេដ្ឋកិច្ចបៃតងប្រកបដោយចីរភាព និងបរិយាបន្ន ការបង្កើតការងារសមរម្យ ការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ តម្លាភាព និងគណនេយ្យភាពតាមរយៈការពង្រឹងសមត្ថភាពស្ថាប័ននៅគ្រប់កម្រិត ការជំរុញឱ្យមានសង្គមស៊ីវិលមានលក្ខណៈសកម្ម និងចម្រុះ និងលើកកម្ពស់អភិក្រមដែលផ្អែកលើលទ្ធផល និងអភិក្រមសិទ្ធិមនុស្ស សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។

ការសម្រេចបាននូវគោលដៅ និងទិសដៅដែលបានកំណត់នៅក្នុងក្របខ័ណ្ឌលទ្ធផលនេះ ទំនងជានឹងរងផលប៉ះពាល់ដោយសារជំងឺរាតត្បាតកូវីដ-១៩។ ទោះជាយ៉ាងនេះក្តី ក្នុងអំឡុងពេលនៃសេចក្តីព្រាងក្របខ័ណ្ឌលទ្ធផលនេះ ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅតែបន្តកើតមានឡើងនៅឡើយ។ ដូច្នេះវាពិបាកក្នុងការប៉ាន់ស្មានផលប៉ះពាល់ដែលជាសក្តានុពលទៅលើការអនុវត្តយុទ្ធសាស្ត្ររួម។ ខ្លឹមសារនៃក្របខណ្ឌលទ្ធផលនឹងត្រូវពិនិត្យ ហើយប្រសិនបើចាំបាច់ នឹងត្រូវកែសម្រួលក្នុងពេលសមស្រប ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើវិស័យផ្សេងៗគ្នា។

| លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប | លទ្ធផលរំពឹងទុក | ដៃគូដែលនាំមុខ និងសកម្ម |
|---|---|---|
| គោលដៅយុទ្ធសាស្ត្រចតុកោណទី ១ (អភិបាលកិច្ច - ស្នូល)៖ បង្កើនការកែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាព បង្កើនគណនេយ្យភាព និងសុចរិតភាពក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ ពង្រឹងប្រសិទ្ធភាពការងារ និងពង្រឹងអភិបាលកិច្ចវិស័យឯកជន។ | | |
| លទ្ធផលយុទ្ធសាស្ត្រអឺរ៉ុប ទី១៖ ពង្រឹងគណនេយ្យភាពប្រជាធិបតេយ្យ សុចរិតភាព និងប្រសិទ្ធភាពនៃប្រព័ន្ធនិងសេវាស្ថាប័នសាធារណៈរបស់កម្ពុជានៅគ្រប់លំដាក់ថ្នាក់ ("ផ្នែកផ្គត់ផ្គង់នៃអភិបាលកិច្ច") ដោយផ្តោតជាពិសេសលើកម្មវិធីកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ រួមទាំងអំពើពុករលួយ។ | | |
| **PFM:**<br>សម្រេចបាននិន័យសារពើពន្ធរួម ការបែងចែកធនធានតាមតម្រូវការអាទិភាព និងការផ្តល់សេវាសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព។ | ភាពជឿជាក់បាននៃថវិកាមានភាពប្រសើរឡើង | <u>EUD</u><br>FR, SE |
| | គណនេយ្យភាពហិរញ្ញវត្ថុប្រសើរឡើង | |
| | ទំនាក់ទំនងគោលនយោបាយ-ថវិកាមានភាពប្រសើរឡើង | |
| **SNDD:**<br>រដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) លើកកម្ពស់ការផ្តល់សេវាជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន រួមចំណែកដល់ការលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។ | លទ្ធផលផ្អែកលើ JMI | <u>DE</u><br>CH, EUD |
| **ទិន្នន័យ និងស្ថិតិ៖**<br>ប្រព័ន្ធស្ថិតិជាតិបំពេញតម្រូវការដែលកំពុងកើនឡើងចំពោះព័ត៌មានស្ថិតិដែលមានគុណភាពខ្ពស់ ទាន់ពេលវេលា និងអាចចូលយកព័ត៌មានបានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង និងការវាស់វែងជាបរិមាណនូវវឌ្ឍនភាពនៃការអភិវឌ្ឍនៅក្នុង CSDG, NSDP និងតម្រូវការទិន្នន័យផ្សេងទៀត។ | អាទិភាពប្រចាំឆ្នាំនៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (NSDS) ឆ្នាំ ២០១៩-២០២៣ ត្រូវបានអនុវត្តយ៉ាងពេញលេញ (JMIs) | <u>SE</u><br>DE, EUD |
| លទ្ធផលយុទ្ធសាស្ត្រអឺរ៉ុប ទី២៖ ជំរុញការចូលរួមបែបប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ និងគាំទ្របរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលនៅកម្ពុជា ("ផ្នែកតម្រូវការនៃអភិបាលកិច្ច")។ | | |

| លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប | លទ្ធផលរំពឹងទុក | ដៃគូដែលនាំមុខ និងសកម្ម |
|---|---|---|
| **សង្គមស៊ីវិល** (រួមបញ្ចូលផែនទីបង្ហាញផ្លូវអង្គការសង្គមស៊ីវិល)<br>បរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលនៅកម្ពុជាត្រូវបានពង្រឹង ហើយដៃគូអឺរ៉ុបគាំទ្រសមត្ថភាពភាពធន់ និងការចូលរួមរបស់អង្គការសង្គមស៊ីវិល។ | លទ្ធផលផ្អែកលើផែនទីបង្ហាញផ្លូវរបស់អង្គការសង្គមស៊ីវិល ដែលត្រូវយល់ព្រមនៅពេលដែលផែនទីបង្ហាញផ្លូវអង្គការសង្គមស៊ីវិលថ្មី បានបង្កើតឡើង។ | ទាំងអស់ |
| **សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី** (រួមបញ្ចូលផែនការសកម្មភាពយេនឌ័រ)<br>គ្រប់ទម្រង់នៃអំពើហិង្សា និងការរើសអើងទាក់ទងយេនឌ័រត្រូវបានកាត់បន្ថយ ខណៈដែលមានការគោរព និងការលើកកម្ពស់សិទ្ធិមនុស្សរបស់ស្ត្រីទាំងអស់ (សេដ្ឋកិច្ច សង្គម វប្បធម៌ នយោបាយ និងស៊ីវិល) នៅគ្រប់មជ្ឈដ្ឋានទទមានការកើនឡើង ដើម្បីឆ្លើយតបទៅនឹង CSDGs។ | លទ្ធផលផ្អែកលើ GAP ដែលនឹងត្រូវយល់ព្រមនៅពេលដែល GAP ថ្មីត្រូវបានបង្កើតឡើង។ | <u>SE</u><br>ទាំងអស់ |
| គោលដៅយុទ្ធសាស្ត្រចតុកោណ ទី២ (ការអភិវឌ្ឍធនធានមនុស្ស – ចតុកោណទី ១)៖ ពង្រឹងគុណភាពនៃការអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ លើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និងពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម. | | |
| <u>លទ្ធផលយុទ្ធសាស្ត្រអឺរ៉ុប ទី៣</u>៖ គាំទ្រដល់ការផ្តល់សេវាកម្មដែលមានគុណភាព ដែលអាចរកបាន និងដែលមានបរិយាបន្ន ដើម្បីពង្រឹងការអភិវឌ្ឍធនធានមនុស្ស ដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ រួមបញ្ចូលការអប់រំ ការអភិវឌ្ឍជំនាញ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សុខភាព អាហារូបត្ថម្ភ និងការគាំពារសង្គម ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសង្គម និងជនបទជាដើម។ | | |
| **ការអប់រំ**<br>គុណភាព លទ្ធភាពទទួលបាន និងបរិយាបន្នកម្មនៃប្រព័ន្ធអប់រំ ព្រមទាំងអត្រាបញ្ចប់ការសិក្សា មានភាពប្រសើរឡើង។ | | |
| *(ការអប់រំមូលដ្ឋាន និងកម្រិតមធ្យមសិក្សា)៖*<br>អត្រាបញ្ចប់ការសិក្សារបស់សិស្សក្នុងការអប់រំមូលដ្ឋានកើនឡើង ជាមួយនឹងលទ្ធផលសិក្សាកាន់តែប្រសើរ។ | លទ្ធផលផ្អែកលើ JMI | <u>EU</u><br>BE, CZ, FR, SE |
| *(ការអប់រំកម្រិតឧត្តមសិក្សា និងការស្រាវជ្រាវ)*<br>គុណភាព និងលទ្ធភាពចូលរៀននៅសាកលវិទ្យាល័យមានភាពប្រសើរឡើង។ | ការលើកកម្ពស់គុណភាព និងលទ្ធភាពចូលរៀននៅសាកលវិទ្យាល័យ។ | <u>FR</u><br>BE, CZ, EU, IE, SE |

| លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប | លទ្ធផលរំពឹងទុក | ដៃគូដែលនាំមុខ និងសកម្ម |
|---|---|---|
| **ការអភិវឌ្ឍជំនាញ/ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)៖**<br>ការទទួលបាន និងគុណភាពនៃ TVET កើនឡើង ដើម្បីបំពេញតាមតម្រូវការទីផ្សារការងារ។ | គុណភាពនៃ TVET ប្រសើរឡើង ដើម្បីបំពេញតាមតម្រូវការទីផ្សារការងារ (JMI) | <u>CH</u><br>CZ, DE, EU, FR, SE |
| | ពង្រីក TVET ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម (JMI) | |
| | ត្រឹមឆ្នាំ២០៣០ ធានាឱ្យមានលទ្ធភាពស្មើគ្នាសម្រាប់ស្ត្រី និងបុរសគ្រប់រូបដើម្បីទទួលបានការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងថ្នាក់ឧត្តមសិក្សាប្រកបដោយគុណភាព និងតម្លៃសមរម្យ រួមទាំងសាកលវិទ្យាល័យផងដែរ (CSDG ៤.៣) | |
| | ពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងវិស័យឯកជន ជាមួយដៃគូផ្សេងទៀត ដើម្បីធានាបាននូវចីរភាព TVET។ (JMI) | |
| **ការគាំពារសង្គម និងសុខភាព**<br>សេវាគាំពារសុខភាព និងសេវាគាំពារសង្គមធានាថាប្រជាពលរដ្ឋទាំងអស់អាចចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍនយោបាយ និងសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា។ | | |
| *(សុខភាព)* | ត្រឹមឆ្នាំ២០៣០ សម្រេចបាននូវកម្រិតរួមមួយនៃការអភិវឌ្ឍសុខភាព និងសុខុមាលភាពរបស់កម្ពុជា និងការការពារហានិភ័យហិរញ្ញវត្ថុលើការគាំពារសុខភាព។<br>(CSDG ៣.១) | <u>DE</u><br>BE, CH, CZ, FR, IE |
| *(សន្តិសុខស្បៀង និងអាហារូបត្ថម្ភ)* | ត្រឹមឆ្នាំ២០៣០ បញ្ចប់រាល់ទម្រង់នៃកង្វះអាហារូបត្ថម្ភ រួមទាំងការសម្រេចបានត្រឹមឆ្នាំ២០២៥ នូវគោលដៅដែលបានព្រមព្រៀងជាអន្តរជាតិស្តីពីភាពក្រិន និងការស្គាំងស្គមចំពោះកុមារអាយុក្រោម ៥ ឆ្នាំ និងដោះស្រាយតម្រូវការអាហារូបត្ថម្ភរបស់ក្មេងស្រីជំទង់ ស្ត្រី | <u>DE</u><br>BE, CZ, EU, FR, IE |

| លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប | លទ្ធផលរំពឹងទុក | ដៃគូដែលនាំមុខ និងសកម្ម |
|---|---|---|
| | មានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន និងមនុស្សចាស់។ (CSDG ២.២) | |
| *(ការគាំពារសង្គម)* | អនុវត្តប្រព័ន្ធគាំពារសង្គម និងវិធានការសមស្របថ្នាក់ជាតិសម្រាប់ទាំងអស់គ្នា រួមទាំងកម្រិតនានា ត្រឹមឆ្នាំ២០៣០ សម្រេចបាននូវវិសាលភាពគ្របដណ្តប់យ៉ាងច្រើនសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (CSDG ១.៣) | DE<br>BE, CZ, EU, FR |
| *(ហេដ្ឋារចនាសម្ព័ន្ធសង្គម និងជនបទ)* | ត្រឹមឆ្នាំ២០៣០ សម្រេចបាននូវលទ្ធភាពទទួលបានការប្រើប្រាស់ទឹកស្អាតដែលមានសុវត្ថិភាព និងតម្លៃសមរម្យសម្រាប់ទាំងអស់គ្នាជាសាកល និងប្រកបដោយសមធម៌ (CSDG ៦.១) | FR<br>CZ, DE, EIB, EU |
| | ត្រឹមឆ្នាំ២០៣០ សម្រេចបាននូវលទ្ធភាពទទួលបានសេវាអនាម័យ និងអនាម័យផ្ទាល់ខ្លួនគ្រប់គ្រាន់ និងប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នា និងបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល ដោយយកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការរបស់ស្ត្រី និងក្មេងស្រី និងអ្នកដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។ (CSDG ៦.២) | |
| | ត្រឹមឆ្នាំ២០៣០ បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកនៅគ្រប់វិស័យ និងធានាឱ្យមានការដកយក និងផ្គត់ផ្គង់ទឹកសាបប្រកបដោយចីរភាព ដើម្បីដោះស្រាយបញ្ហាខ្វះខាតទឹក និងកាត់បន្ថយបានយ៉ាងច្រើននូវចំនួនប្រជាជនដែលទទួលរងការខ្វះខាតទឹក (CSDG ៦.៤) | |

គោលដៅយុទ្ធសាស្ត្រចតុកោណ ទី៣ (ការធ្វើពិពិធកម្មសេដ្ឋកិច្ច – ចតុកោណ ទី២)៖ កែលម្អប្រព័ន្ធឡូជីស្ទីក និងលើកកម្ពស់ការតភ្ជាប់ ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល។ អភិវឌ្ឍប្រភពចំបងថ្មីៗនៃកំណើនសេដ្ឋកិច្ច រៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម ទី៤ និងជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ។

| លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប | លទ្ធផលរំពឹងទុក | ដៃគូដែលនាំមុខ និងសកម្ម |
|---|---|---|
| និង<br><br>គោលដៅយុទ្ធសាស្ត្រចតុកោណ ទី៤ (វិស័យឯកជន និងការអភិវឌ្ឍការងារ – ចតុកោណ ទី៣)៖ អភិវឌ្ឍទីផ្សារការងារ លើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព រៀបចំ និងអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន និងពង្រឹងការប្រកួតប្រជែង។ | | |
| <u>លទ្ធផលយុទ្ធសាស្ត្រអឺរ៉ុប ទី៤</u>៖ បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារក្នុងតំបន់ និងសាកលតាមរយៈការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិស័យឯកជន បង្កលក្ខណៈងាយស្រួលដល់បរិយាកាសធុរកិច្ច និងផលិតកម្មប្រកបដោយចីរភាព ក៏ដូចជាការអនុវត្តការងារសមរម្យស្របតាមស្តង់ដារអន្តរជាតិ។ | | |
| **ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិស័យឯកជន**<br>***(រួមទាំងបរិយាកាសធុរកិច្ច)៖***<br>ដើម្បីគាំទ្រនិងសម្របសម្រួលការតភ្ជាប់កាន់តែប្រសើរ លើវិស័យពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសអាស៊ានដទៃទៀត ការពង្រឹងសមត្ថភាពស្ថាប័នរបស់កម្ពុជា និងការចូលរួមរបស់វិស័យឯកជន និងគាំទ្រការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ | លទ្ធផលផ្អែកលើ JMI | <u>EU</u><br>CH, DE, FR |
| **ផលិតកម្មប្រកបដោយចីរភាព និងការងារសមរម្យ៖**<br>ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កម្មករនិយោជិត រួមទាំងការទទួលបានមធ្យោបាយផ្លូវច្បាប់មានភាពប្រសើរឡើង។ | ការពារសិទ្ធិការងារ និងលើកកម្ពស់បរិយាកាសការងារដែលមានសុវត្ថិភាព និងសន្តិសុខសម្រាប់កម្មករនិយោជិតទាំងអស់ រួមទាំងពលករចំណាកស្រុក ជាពិសេសស្ត្រីចំណាកស្រុក និងអ្នកដែលស្ថិតក្នុងការងារមិនមានសុវត្ថិភាព (CSDG ៨.៨) | <u>DE</u><br>BE, CH, EU, FR, SE |
| **សេវាកម្មហិរញ្ញវត្ថុ**<br>អភិក្រម និងសមត្ថភាពប្រកបដោយនចីរភាពត្រូវបានបង្កើតឡើង ដើម្បីបម្រើដល់សហគ្រាសខ្នាតតូចនៅតំបន់ជនបទ។ | មានភាពប្រសើរឡើងចំពោះលទ្ធភាពទទួលបាន និងការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុដែលមានភាពងាយស្រួល តម្លៃសមរម្យ និងបានផ្តល់ជូនប្រកបដោយការទទួលខុសត្រូវ ដើម្បីបម្រើដល់សហគ្រាសខ្នាតតូចនៅតំបន់ជនបទ។ | <u>AFD</u> |
| គោលដៅយុទ្ធសាស្ត្រចតុកោណ ទី៥ (ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន – ចតុកោណទី ៤)៖ លើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ធានាការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព ពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និងធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ | | |

| លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប | លទ្ធផលរំពឹងទុក | ដៃគូដែលនាំមុខ និងសកម្ម |
|---|---|---|
| <u>លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប ទី៥៖</u> ការអភិវឌ្ឍបៃតងប្រកបដោយចីរភាព រួមមានការគ្រប់គ្រងធនធានធម្មជាតិរបស់កម្ពុជា ការការពារ និងអភិរក្សបរិស្ថាន ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ ផ្សព្វផ្សាយអំពីថាមពលបៃតង ប្រសិទ្ធភាពថាមពល ការអភិវឌ្ឍប្រកបដោយចីរភាពលើវិស័យកសិកម្ម វារីវប្បកម្ម ជលផល ព្រៃឈើ ព្រមទាំងការបោសសម្អាតមីននៅក្នុងប្រទេសកម្ពុជា។ | | |
| **កសិកម្ម វារីវប្បកម្ម ជលផលនិង ព្រៃឈើ**<br>ការបង្កើនផលិតភាព ការធ្វើពិពិធកម្ម និងការគាំទ្រប្រកបដោយគុណភាពដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ជីវភាពរស់នៅប្រកបដោយចីរភាព និងការអភិវឌ្ឍជនបទប្រកបដោយសមធម៌។<br>(ref. TEI1) | | |
| *(កសិកម្ម)* | ផលិតភាព និងការធ្វើពិពិធកម្មកសិកម្ម និងបរិមាណនាំចេញវិស័យកសិកម្មមានភាពប្រសើរឡើង (JMI) | <u>FR</u><br>BE, CH, DE, EUD, EIB |
| | កែលម្អការគ្រប់គ្រងធនធានទឹក (ប្រតិបត្តិការ និងការថែទាំ[O&M] និងការអភិវឌ្ឍសហគមន៍កសិករប្រើប្រាស់ទឹក [FWUC]) ការអភិវឌ្ឍ និងការពង្រីកប្រព័ន្ធធារាសាស្ត្រ។ (JMI) | |
| *(វារីវប្បកម្ម និងជលផល)* | ផលិតកម្មពីការនេសាទត្រីធម្មជាតិត្រូវបានរក្សា (JMI/NSDP) | <u>EU</u><br>CH, DE, FR |
| | ផលិតកម្មវារីវប្បកម្មកើនឡើង ២០% ជារៀងរាល់ឆ្នាំ (JMI) | |
| *(ព្រៃឈើ)* | ផលិតកម្មប្រកបដោយចីរភាព និងការគ្រប់គ្រងព្រៃឈើសហគមន៍មានភាពប្រសើរឡើង (JMI) | <u>EU</u><br>BE, CH, EIB, SE |
| | ត្រឹមឆ្នាំ២០២០ ធានានូវការស្តារការអភិវឌ្ឍ និងការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីទឹកសាបលើដី និងការបម្រើជា | |

| លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប | លទ្ធផលរំពឹងទុក | ដៃគូដែលនាំមុខ និងសកម្ម |
|---|---|---|
| | ប្រយោជន៍ ជាពិសេសព្រៃឈើ ដីសើម ភ្នំ និង ដីស្ងួត ឱ្យស្របតាមកាតព្វកិច្ចនៃកិច្ចព្រមព្រៀងអន្តរជាតិ (CSDG ១៥.១) | |
| **ការគ្រប់គ្រងធនធានធម្មជាតិ ការការពារ និងអភិរក្សបរិស្ថាន**<br>ធនធានធម្មជាតិរបស់កម្ពុជាត្រូវបានការពារ និង គ្រប់គ្រងប្រកបដោយចីរភាព។<br>(Ref TEI 1) | ជីវចម្រុះអាស្រ័យផលព្រៃឈើត្រូវបានការពារ និងកែលម្អ (JMI) | EU<br>BE, CH, FR, SE |
| **ការបោសសម្អាតមីន**<br>កម្ពុជាជាប្រទេសដែលគ្មានមីន ហើយការគំរាមកំហែងដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាមត្រូវបានកាត់បន្ថយជាអតិបរមា ហើយការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ច-សង្គមធ្វើឡើងដោយសុវត្ថិភាព។ | ដោះមីនពីគ្រប់តំបន់ទាំងអស់ដែលគេដឹងថាមានគ្រាប់មីន។ (JMI) | CH<br>BE, DE, IE |
| | រំដោះតំបន់អាទិភាពមិនឱ្យមានគ្រាប់បែកចង្កោម (JMI) | |
| | កម្ពុជាជាប្រទេសដែលគ្មានមីននៅត្រឹមឆ្នាំ ២០២៥ ស្របតាមយុទ្ធសាស្ត្រជាតិសកម្មភាពមីន ឆ្នាំ២០១៨-២០២៥ (CSDG ១៨) | |
| **ការប្រែប្រួលអាកាសធាតុ និង DRR**<br>កម្ពុជាបំពេញតាមលក្ខខណ្ឌតម្រូវរបស់ UNFCCC។ | NDC ដែលត្រូវបានកែសម្រួលរបស់កម្ពុជាត្រូវបានដាក់ជូនស្របតាមលក្ខខណ្ឌតម្រូវរបស់ UNFCCC (JMI) | EU<br>CH, DE, FR, SE |
| | ប្រព័ន្ធពិនិត្យតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់របស់កម្ពុជាសម្រាប់ការប្តេជ្ញាចិត្តរបស់ខ្លួននៅក្រោម NDC មានដំណើរការ (JMI) | |
| **ថាមពលបៃតង និងប្រសិទ្ធភាពថាមពល**<br>ការអនុញ្ញាតឱ្យចូលប្រើ និងប្រើប្រាស់សេវាកម្មថាមពលដែលមានតម្លៃសមរម្យ ប្រកបដោយបរិយាបន្ន និងចីរភាពមានការកើនឡើង។<br>(Ref TEI 2) | ត្រឹមឆ្នាំ២០៣០ បង្កើនចំណែកនៃថាមពលកកើតឡើងវិញឱ្យបានច្រើននៅក្នុងល្បាយថាមពលសាកលប្រកបដោយចីរភាព (CSDG ៧.២) | FR<br>DE, EIB, EU |
| | ត្រឹមឆ្នាំ២០៣០ បង្កើនទ្វេដងនូវអត្រាសាកលនៃការកែលម្អប្រសិទ្ធភាពថាមពល (CSDG ៧.៣) | |
| <u>លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុបទី ៦៖</u> ការគាំទ្រយ៉ាងសកម្ម និងប្រកបដោយការសម្របសម្រួលសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ដោយផ្តោតជាពិសេសលើ តែមិនកំណត់ត្រឹមតំបន់អង្គរទេ។ | | |

| លទ្ធផលយុទ្ធសាស្ត្ររបស់អឺរ៉ុប | លទ្ធផលរំពឹងទុក | ដៃគូដែលនាំមុខ និងសកម្ម |
|---|---|---|
| **បេតិកភណ្ឌវប្បធម៌**<br>បេតិកភណ្ឌវប្បធម៌ខ្មែរត្រូវបានអភិរក្ស និងសមត្ថភាពអភិរក្សកើនឡើង។ | ពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីការពារ និងថែរក្សាបេតិកភណ្ឌវប្បធម៌ និងធម្មជាតិរបស់ពិភពលោក (CSDG ១១.៤) | FR<br>DE |

# ការរៀបចំការពិនិត្យតាមដាន និងការវាយតម្លៃ

ការពិនិត្យតាមដានលទ្ធផលត្រូវបានជូនដំណឹងតាមរយៈដំណើរការពិនិត្យតាមដានរួមគ្នារបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលបានឯកភាព និងពិនិត្យតាមដានរួមគ្នាតាមរយៈយន្តការក្រុមការងារបច្ចេកទេសពាក់ព័ន្ធ (TWG)។ ការវាយតម្លៃលទ្ធផលត្រូវបានជូនដំណឹងផងដែរតាមរយៈការរៀបចំការពិនិត្យតាមដាន និងវាយតម្លៃផ្ទាល់របស់ដៃគូអឺរ៉ុប ដែលធ្វើការទាក់ទងនឹងផ្នែកកម្មវិធី និងគម្រោងរៀងៗខ្លួន។ រូបភាពទូលំទូលាយអំពីការផ្លាស់ប្តូរនៃទិសដៅរួម នៅក្នុងកំណែទម្រង់ស្ថូល និងនៅទូទាំងវិស័យក៏នឹងត្រូវពិចារណាផងដែរ នៅពេលវាយតម្លៃវឌ្ឍនភាពរួម និងផលប៉ះពាល់នៃការអនុវត្តយុទ្ធសាស្ត្ររួម។

របាយការណ៍ពាក់កណ្តាលអាណត្តិទីមួយនៃយុទ្ធសាស្ត្របច្ចុប្បន្ននឹងគ្របដណ្តប់រយៈពេល ឆ្នាំ២០២១-២០២៣ ហើយនឹងត្រូវបានបន្តដោយរបាយការណ៍ទីពីរដែលគ្របដណ្តប់ឆ្នាំ ២០២៤-២០២៧។ លទ្ធផលរកឃើញនៃរបាយការណ៍នេះនឹងត្រូវបង្ហាញ និងពិភាក្សាជាមួយភាគីពាក់ព័ន្ធទាំងអស់ មានដូចជារាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល តំណាងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍។

ដៃគូអឺរ៉ុបរក្សានូវលទ្ធភាពក្នុងការពិនិត្យមើល និងកែសម្រួលយុទ្ធសាស្ត្រ និងក្របខ័ណ្ឌលទ្ធផលដែលពាក់ព័ន្ធ នៅពេលណាដែលចាំបាច់ ដើម្បីធានាបាននូវសង្គតិភាព និងការបន្ស៊ីជាមួយបរិបទសេដ្ឋកិច្ច-សង្គម និងជាមួយគោលនយោបាយ និងអាទិភាពរបស់រដ្ឋាភិបាល។

# ឧបសម្ព័ន្ធ ២៖ ការព្យាករហិរញ្ញវត្ថុតាមការចង្អុលបង្ហាញ

| ដៃគូអឺរ៉ុប | បានប្តេជ្ញាចិត្តរួចហើយ | | | | | | | | | | ការបង្ហាញពីការរួមចំណែកថ្មី | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | BE | CH | CZ(៥) | DE | EIB | EU | FR | IE | SE(៤) | ផលបូក | CH | CZ | DE | EIB | EU | FR | IE | SE | ផលបូក | |
| **វិស័យអាទិភាព ទី១ - ផ្នែកផ្គត់ផ្គង់នៃអភិបាលកិច្ច** | **-** | **2.85** | **-** | **6.50** | **-** | **34.19** | **2.61** | **-** | **4.50** | ***50.66*** | **7** | **0** | **0** | **0** | **37** | **0** | **0** | **0** | ***44*** | **94.66** |
| បរិការ និងការគាំទ្រ BoP | | - | - | - | | 18.56 | - | - | - | *18.56* | | | | | | | | | *0* | 18.56 |
| គោលនយោបាយ/ផែនការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ | | - | - | | | 0.04 | 1.05 | - | | *1.09* | | | | | | | | | *0* | 1.09 |
| ផ្លូវច្បាប់ និងតុលាការ | | - | - | 0.50 | | 2.84 | - | - | - | *3.34* | | | | | | | | | *0* | 3.34 |
| កំណែទម្រង់រដ្ឋាភិបាលមូលដ្ឋាន | | 2.84 | - | 6.00 | | 0.24 | - | - | - | *9.08* | | | | | | | | | *0* | 9.08 |
| ផ្សេងៗ | | 0.01 | - | - | | - | - | - | - | *0.01* | | | | | | | | | *0* | 0.01 |
| ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | - | - | - | | 12.51 | 1.56 | - | 4.50 | *18.58* | | | | | | | | | *50* | 68.58 |
| **វិស័យអាទិភាព ទី២ - ផ្នែកតម្រូវការនៃអភិបាលកិច្ច** | **-** | **-** | **-** | **-** | **-** | **1.34** | **-** | **-** | **19.70** | ***21.04*** | **7** | **0** | **0** | **0** | **0** | **0** | **0** | **50** | ***57*** | **78.04** |
| សង្គមស៊ីវិល | | - | - | - | | 0.31 | - | - | 8.60 | *8.91* | 1.3 | | | | | | | | *1.3* | 10.21 |
| យេនឌ័រ | | - | - | - | | 0.48 | - | - | 1.00 | *1.48* | | | | | | | | | *0* | 1.48 |
| សិទ្ធិមនុស្ស | | - | - | - | | 0.55 | - | - | 10.10 | *10.65* | | | | | | | | | *0* | 10.65 |
| **វិស័យអាទិភាព ទី៣ - ការអភិវឌ្ឍមនុស្ស** | **-** | **14.12** | **4.76** | **#####** | **181.49** | **56.04** | **191.29** | **0.10** | **1.20** | ***554.00*** | **19.9** | **2.59** | **0** | **0** | **48** | **0** | **0** | **0** | ***70.49*** | **624.49** |
| ការអភិវឌ្ឍសហគមន៍ | | 0.02 | - | - | | 1.54 | - | - | - | *1.56* | | | | | | | | | *0* | 1.56 |
| ការអប់រំ (រួមទាំង TVET) | - | 9.11 | 2.59 | 25.00 | | 40.26 | 0.61 | - | 1.20 | *78.77* | 4.7 | 1.71 | | | | | | | *6.41* | 85.18 |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀង | | 0.93 | - | 18.30 | | - | - | - | - | *19.23* | | | | | | | | | *0* | 19.23 |
| សុខភាព | - | 3.97 | 1.33 | 24.00 | | | 0.85 | 0.10 | - | *30.25* | 15.2 | 0.64 | | | | | | | *15.84* | 46.09 |
| ផ្សេងៗ | | - | - | 2.70 | | 0.35 | - | - | - | *3.05* | | | | | | | | | *0* | 3.05 |
| ការគាំពារសង្គម | - | 0.08 | - | 35.00 | | 7.78 | - | - | - | *42.87* | | | | | | | | | *0* | 42.87 |
| នគរូបនីយកម្ម និងការគ្រប់គ្រងទីក្រុង | | - | - | - | | 0.26 | 20.63 | - | - | *20.89* | | | | | | | | | *0* | 20.89 |
| ទឹក និងអនាម័យ | | - | 0.84 | - | 181.49 | 5.84 | 169.21 | - | - | *357.38* | | 0.24 | | | | | | | *0.24* | 357.62 |
| **វិស័យអាទិភាព ទី៤ - ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិស័យឯកជន** | **-** | **0.48** | **-** | **10.52** | **65.25** | **4.98** | **1.64** | **-** | **-** | ***82.87*** | **0** | **0** | **0** | **0** | **62** | **0** | **0** | **0** | ***62*** | **144.87** |
| សេវាកម្មអាជីវកម្ម និងហិរញ្ញវត្ថុ | | 0.01 | - | - | | 0.25 | 0.26 | - | - | *0.52* | | | | | | | | | *0* | 0.52 |
| ឧស្សាហូបនីយកម្ម និងពាណិជ្ជកម្ម | - | - | - | 10.52 | | 4.37 | - | - | - | *14.89* | | | | | | | | | *0* | 14.89 |
| បច្ចេកវិទ្យា ព័ត៌មាន និងទំនាក់ទំនង | | - | - | - | | 0.36 | - | - | - | *0.36* | | | | | | | | | *0* | 0.36 |
| ទេសចរណ៍ | | 0.47 | - | - | | - | 0.92 | - | - | *1.39* | | | | | | | | | *0* | 1.39 |
| ការដឹកជញ្ជូន | | - | - | - | 65.25 | - | 0.46 | - | - | *65.71* | | | | | | | | | *0* | 65.71 |
| **វិស័យអាទិភាព ទី៥ - កិច្ចព្រមព្រៀងបៃតង** | **-** | **6.53** | **0.84** | **17.00** | **-** | **83.83** | **#####** | **0.52** | **3.50** | ***452.03*** | **7.4** | **0.6** | **0** | **0** | **0** | **0** | **0** | **0** | ***8*** | **460.03** |
| កសិកម្ម | | 6.52 | 0.46 | | | 56.91 | ##### | - | - | *265.34* | | 0.2 | | | | | | | *0.2* | 265.54 |
| ការប្រែប្រួលអាកាសធាតុ | | - | 0.16 | 15.00 | | 3.96 | 25.78 | - | - | *44.90* | 5.2 | 0.32 | | | | | | | *5.52* | 50.42 |
| ថាមពល និងអគ្គិសនី | | - | 0.22 | | | 4.49 | 72.52 | - | - | *77.23* | | 0.08 | | | | | | | *0.08* | 77.31 |
| បរិស្ថាន និងជីវភាព | - | 0.01 | - | | | 4.95 | 19.13 | - | 3.50 | *27.58* | | | | | | | | | *0* | 27.58 |
| អភិវឌ្ឍន៍ជនបទ | - | - | - | 2.00 | | 13.53 | 20.93 | 0.52 | - | *36.97* | 2.2 | | | | | | | | *2.2* | 39.17 |
| **វិស័យអាទិភាព ទី៦ - បេតិកភណ្ឌវប្បធម៌** | **-** | **-** | **-** | **-** | **-** | **-** | **1.18** | **-** | **-** | ***1.18*** | **0.3** | **0** | **0** | **0** | **0** | **0** | **0** | **0** | ***0.3*** | **1.48** |
| វប្បធម៌ សិល្បៈ និងកីឡា | | - | - | - | | - | 1.18 | - | - | *1.18* | 0.3 | | | | | | | | *0.3* | 1.48 |
| **ផ្សេងៗ** | | **-** | **-** | **1.00** | | **-** | **-** | **-** | **-** | ***1.00*** | **1** | | | | **8** | | | | ***9*** | **10.00** |
| **សរុប** | **-** | **23.98** | **5.60** | **#####** | **246.74** | **#####** | **#####** | **0.62** | **28.90** | ***1,162.77*** | **42.6** | **3.19** | **0** | **0** | **155** | **0** | **0** | **50** | ***250.8*** | **1,413.56** |

(១) ប្រទេសស្វីស ៖ តួលេខចង្អុលបង្ហាញគឺជាមូលនិធិដែលមិនទាន់បានប្តេជ្ញាចិត្តជាផ្លូវការ ប៉ុន្តែថវិកានេះត្រូវបានចង្អុលបង្ហាញសម្រាប់កម្មវិធីកិច្ចសហប្រតិបត្តិការតំបន់មេគង្គ (រួមទាំងប្រទេសកម្ពុជា) សម្រាប់ឆ្នាំ ២០២២-២០២៥។ ពុំទាន់មានថវិកាបង្ហាញណាមួយសម្រាប់ឆ្នាំ ២០២៦ និងឆ្នាំ ២០២៧ ទេ។

(២) សហភាពអឺរ៉ុប - ចំនួនមូលនិធិសំដៅទៅលើតែរយៈពេលឆ្នាំ ២០២១-២០២៤ ប៉ុណ្ណោះ។ ការបែងចែកថវិកាសម្រាប់ឆ្នាំ ២០២៥-២០២៧ មិនទាន់បញ្ជាក់នៅឡើយទេ។

(៣) BE នឹងដឹងច្បាស់អំពីមូលនិធិដែលប្តេជ្ញាចិត្តនៅត្រឹមចុងឆ្នាំ ២០២១។

(៤) SE មូលនិធិដែលរួមចំណែកថ្មីឆ្នាំ២០២១-២០២៤នឹងធ្វើបច្ចុប្បន្នភាពក្នុងខែមេសា ឆ្នាំ២០២២។ សម្រាប់ថវិកាវិស័យអប់រំបានធ្វើបច្ចុប្បន្នភាពនៅត្រីមាសទី១-២ ឆ្នាំ២០២១។

(៥) CZ ចំនួនមូលនិធិសំដៅទៅលើតែរយៈពេលឆ្នាំ ២០២១-២០២៤ ប៉ុណ្ណោះ។ ការបែងចែកថវិកាសម្រាប់ឆ្នាំ ២០២៥-២០២៧ មិនទាន់បញ្ជាក់នៅឡើយទេ។

# ឧបសម្ព័ន្ធ ៣ - យុទ្ធសាស្ត្រអឺរ៉ុបរួម ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជា ឆ្នាំ ២០២១-២០២៧ – វិស័យអាទិភាព និង វិស័យទាក់ទងនឹងវិស័យ OECD DAC5 និង SDGS

| **ការបន្សុំជាមួយ RS4** | **វិស័យអាទិភាពរបស់យុទ្ធសាស្ត្រអឺរ៉ុបរួម JES** | **វិស័យ DAC** | **SDGs** | **ដៃគូអភិវឌ្ឍន៍របស់សហភាពអឺរ៉ុបឈានមុខ** | **ដៃគូអភិវឌ្ឍន៍របស់សហភាពអឺរ៉ុបសកម្ម** | **ដៃគូអភិវឌ្ឍន៍ផ្សេងៗ (និងត្រូវបញ្ចប់)** |
|---|---|---|---|---|---|---|
| **ស្នូលសំខាន់សម្រាប់ RS4៖ គាំទ្រការបង្កើនល្បឿននៃកំណែទម្រង់អភិបាលកិច្ច** | **វិស័យអាទិភាព ទី១ - ពង្រឹងគណនេយ្យភាពបែបប្រជាធិបតេយ្យ សុចរិតភាព និងប្រសិទ្ធភាពនៃប្រព័ន្ធ និងសេវាស្ថាប័នសាធារណៈរបស់កម្ពុជានៅគ្រប់លំដាប់ថ្នាក់ ("ផ្នែកផ្គត់ផ្គង់នៃអភិបាលកិច្ច") ដោយផ្តោតជាពិសេសលើកម្មវិធីកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ រួមទាំងអំពើពុករលួយ។** | | | | | |
| | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) | រដ្ឋាភិបាល និងសង្គមស៊ីវិល (១៥១) | ១៦.៦ | EU | FR, SE[1] | ADB, AUS, WB |
| | ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (SNDD រួមទាំង ISAF) | រដ្ឋាភិបាល និងសង្គមស៊ីវិល (១៥១) | ១៦.៦ | CH, DE | CH, EU | ADB, CAN, WB, ILO, JAP, KOR, UNDP, USA |
| | ទិន្នន័យ និងស្ថិតិ | រដ្ឋាភិបាល និងសង្គមស៊ីវិល (១៥១) ហេដ្ឋារចនាសម្ពន្ធ័និងសេវាកម្មសង្គមផ្សេងៗ | ១៧.១៨, ១៧.១៩ | SE[2] | EU, DE | |
| | អំពើពុករលួយ | រដ្ឋាភិបាល និងសង្គមស៊ីវិល (១៥១) | ១៦.៥ | SE | EU | USAID |
| **ការបន្សុំជាមួយ RS4** | **វិស័យអាទិភាពរបស់យុទ្ធសាស្ត្រអឺរ៉ុបរួម JES** | **វិស័យ DAC** | **SDGs** | **ដៃគូអភិវឌ្ឍន៍របស់សហភាពអឺរ៉ុបឈានមុខ** | **ដៃគូអភិវឌ្ឍន៍របស់សហភាពអឺរ៉ុបសកម្ម** | **ដៃគូអភិវឌ្ឍន៍ផ្សេងៗ (និងត្រូវបញ្ចប់)** |
| | លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស | រដ្ឋាភិបាល និងសង្គមស៊ីវិល (១៥១) | ៥.៧, ១០.៣, ១៦.១០, ១៦.a, ១៦.b | SE | ទាំងអស់ | OHCHR |
| | **វិស័យអាទិភាព ទី២ – ជំរុញការចូលរួមបែបប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ និងគាំទ្របរិយាកាសអំណោយផលសម្រាប់សង្គមស៊ីវិលនៅកម្ពុជា ("ផ្នែកតម្រូវការនៃអភិបាលកិច្ច")** | | | | | |
| | សង្គមស៊ីវិល (រួមទាំងផែនទីបង្ហាញផ្លូវអង្គការសង្គមស៊ីវិល) | រដ្ឋាភិបាល និងសង្គមស៊ីវិល (១៥១) | ១៧.១៧ | EU | ទាំងអស់ | JAP, KOR, UNDP, USA |
| | សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (រួមទាំង GAP) | រដ្ឋាភិបាល និងសង្គមស៊ីវិល (១៥១) | ៥ | SE | ទាំងអស់ | AUS, ILO, JAP, UN Women, UNDP, UNIDO, USA |
| **បុព្វការណ ទី១៖ ការអភិវឌ្ឍសង្គម និងធនធានមនុស្ស** | **វិស័យអាទិភាព ទី៣ – គាំទ្រដល់ការផ្តល់សេវាកម្មដែលមានគុណភាព ភាពអាចរកបាន និងដែលមានបរិយាបន្ន ដើម្បីពង្រឹងការអភិវឌ្ឍធនធានមនុស្សដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ រួមទាំងការអប់រំ ការអភិវឌ្ឍជំនាញ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សុខភាព អាហារូបត្ថម្ភ និងការគាំពារសង្គម ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធសង្គម និងជនបទ។** | | | | | |
| | ការអប់រំ (រួមទាំងការអប់រំកម្រិតឧត្តមសិក្សា) ការសិក្សាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ការអប់រំ (១១០) អាហារូបករណ៍, ពហុវិស័យ (៤៣០) ការស្រាវជ្រាវ, ពហុវិស័យ (៤៣០) | ៤ | EU | BE, CZ, FR, IE | AUS, CAN, ចិន, ILO, KOR, JAP, NZ, UNESCO, USA, WB |
| | | | | FR (កម្រិតឧត្តម) | BE, CZ, EU, HU | ADB, AUS |

[1] រហូតដល់ឆ្នាំ២០២២

[2] រហូតដល់ឆ្នាំ២០២២ បន្ទាប់មកសហភាពអឺរ៉ុប (EU) នឹងនាំមុខ

| ការបន្សី ជាមួយ RS4 | វិស័យអាទិភាពរបស់ យុទ្ធសាស្ត្រអឺរ៉ុបរួម JES | វិស័យ DAC | SDGs | ដៃគូអភិវឌ្ឍន៍របស់ សហភាពអឺរ៉ុប ឈានមុខ | ដៃគូអភិវឌ្ឍន៍របស់ សហភាពអឺរ៉ុប សកម្ម | ដៃគូអភិវឌ្ឍន៍ ផ្សេងៗ (នឹង ត្រូវបញ្ចប់) |
|---|---|---|---|---|---|---|
| | TVET/ ការអភិវឌ្ឍ ជំនាញ | TVET/SD (១១៣) | ៤.៣/៤.៤ | CH | CZ, EU, FR, DE, HU | UNESCO |
| | សុខភាព (រួមទាំងការ ឆ្លើយតបទៅនឹងកូវីដ-១៩) | សុខភាព (១២០)<br>ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គម ផ្សេងទៀត (១៦០) | ៣, ៣.៣ (សុខភាព)<br>៥.៦ (SRH) | DE | BE, CH, CZ, FR, HU, IE, EU | ADB, CAN, ចិន, GAVI, GF, ILO, JAP, KOR, UK, UNDP, UNICEF, UNIDO, USA, WB |
| | សន្តិសុខស្បៀង និង អាហារូបត្ថម្ភ | ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គម ផ្សេងទៀត (១៦០) | ២, ២.២ (FSN) | DE | CH, IE | CAN, FAO, IEA, JAP, WFP, WB |
| | ការគាំពារសង្គម | ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គម ផ្សេងទៀត (១៦០) | ១.៣ (កិច្ចគាំពារ សង្គម) | DE | BE | UNDP |
| | ហេដ្ឋារចនាសម្ព័ន្ធសង្គម និងជនបទ | ការផ្គត់ផ្គង់ទឹក និងអនាម័យ (១៤០)<br>ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គម ផ្សេងទៀត (១៦០)<br>ការអភិវឌ្ឍជនបទ ពហុវិស័យ (៤៣០) | ៦.៥ (ទឹក) | FR | CZ, EIB, EU | ADB, ចិន, IAEA, JAP, KOR, USA, WB |
| ការបន្សី ជាមួយ RS4 | វិស័យអាទិភាពរបស់ យុទ្ធសាស្ត្រអឺរ៉ុបរួម JES | វិស័យ DAC | SDGs | ដៃគូអភិវឌ្ឍន៍របស់ សហភាពអឺរ៉ុប ឈានមុខ | ដៃគូអភិវឌ្ឍន៍របស់ សហភាពអឺរ៉ុប សកម្ម | ដៃគូអភិវឌ្ឍន៍ ផ្សេងៗ (នឹង ត្រូវបញ្ចប់) |
| ពិពិធកម្មសេដ្ឋកិច្ច (បុព្វការណ ទី២) ការអភិវឌ្ឍ វិស័យឯកជន និង ទីផ្សារ (បុព្វការណ ទី៣) | **វិស័យអាទិភាពទី ៤ - បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងទីផ្សារក្នុងតំបន់ និងសាកលលោក តាមរយៈការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិស័យឯកជន បង្កលក្ខណៈងាយស្រួលដល់បរិយាកាសធុរកិច្ច និងផលិតកម្មប្រកបដោយចីរភាព ក៏ដូចជាការអនុវត្តការងារសមរម្យស្របតាមស្តង់ដារអន្តរជាតិ។** | | | | | |
| | ការអភិវឌ្ឍវិស័យ ពាណិជ្ជកម្ម និងវិស័យ ឯកជន | ឧស្សាហកម្ម (៣២១)<br>គោលនយោបាយ និងបទប្បញ្ញត្តិ ពាណិជ្ជកម្ម (៣៣១) | ១២b (ទេសចរណ៍)<br>៤.៧ (NRM)<br>៨a EIF | EU | CH, CZ, DE, FR (AFD) | ADB, CAN, ចិន, Kora, USA |
| | ផលិតកម្មប្រកបដោយ ចីរភាព និងការងារ សមរម្យ | វិស័យកាត់ដេរ (៣២១)<br>ទេសចរណ៍ (៣៣២)<br>ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គម ផ្សេងទៀត (១៦០) | ១.១ (ភាពក្រីក្រ)<br>៤.៧ (NRM)<br>៥.៥. (ការចូលរួម របស់ស្ត្រី)<br>៨.៣ (ការងារ)<br>១០.១ (កំណើន ប្រកបដោយ បរិយាបន្ន)<br>១២b (ទេសចរណ៍) | FR (AFD) | BE, CH, CZ, EU, FR, SE | ADB, ILO, USA |
| | សេវាកម្មហិរញ្ញវត្ថុ | សេវាកម្មធនាគារ និងហិរញ្ញវត្ថុ (២៤០)<br>សេវាកម្មអាជីវកម្ម និងសេវាកម្ម ផ្សេងទៀត (២៥០) | ៨.២, ៩.៣<br>៨.៣ ទំនើបកម្ម | FR (AFD) | | ADB |

| ការបន្សី ជាមួយ RS4 | វិស័យអាទិភាពរបស់ យុទ្ធសាស្ត្រអឺរ៉ុបរួម JES | វិស័យ DAC | SDGs | ដៃគូអភិវឌ្ឍន៍របស់ សហភាពអឺរ៉ុប ឈានមុខ | ដៃគូអភិវឌ្ឍន៍របស់ សហភាពអឺរ៉ុប សកម្ម | ដៃគូអភិវឌ្ឍន៍ ផ្សេងៗ (នឹង ត្រូវបញ្ចប់) |
|---|---|---|---|---|---|---|
| ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន (ចតុកោណ ទី៤) | **វិស័យអាទិភាព ទី៥ – ការអភិវឌ្ឍបៃតងប្រកបដោយចីរភាព រួមមានការគ្រប់គ្រងធនធានធម្មជាតិ ការការពារ និងអភិរក្សបរិស្ថាន ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ ផ្សព្វផ្សាយអំពីថាមពលបៃតង ប្រសិទ្ធភាពថាមពល ការអភិវឌ្ឍ ប្រកបដោយចីរភាពលើវិស័យកសិកម្ម វារីវប្បកម្ម ជលផល ព្រៃឈើ និងការបោសសម្អាតមីននៅប្រទេសកម្ពុជា។** | | | | | |
| | ការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ (កសិកម្ម ព្រៃឈើ ជលផល បសុសត្វ) | កសិកម្ម ព្រៃឈើ ជលផល បសុសត្វ (៣១០) | ២a, ១២.៣ ១៤.៤ (នេសាទសមុទ្រ IUU) | FR (កសិកម្ម) | BE, DE, HU, CH, EU, EIB, SE | ADB, AUS, CAN, ចិន, FAO, IAEA, IFAD, JP, NZ, KOR, UNDP, UNIDO, USA, WFP |
| | | | | EU (វារីវប្បកម្ម/ ជលផល) | FR, DE, HU, CH | FAO, UNIDO, USA, |
| | | | | EU (ព្រៃឈើ) | BE, CH, EIB, SE | FAO, UNDP, USA |
| | ការគ្រប់គ្រងធនធានធម្មជាតិ ការការពារ និង អភិរក្សបរិស្ថាន | ការការពារបរិស្ថានជាទូទៅ (៤១០) | ១៥ (ប្រព័ន្ធអេកូឡូស៊ីលើដី) ១៤.២ (ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងឆ្នេរសមុទ្រ) ៥.a (សិទ្ធិស្ត្រីចំពោះធនធានសេដ្ឋកិច្ច) | EU | BE, CH, FR, SE | JAP, UNDP, CAN |
| ការបន្សី ជាមួយ RS4 | វិស័យអាទិភាពរបស់ យុទ្ធសាស្ត្រអឺរ៉ុបរួម JES | វិស័យ DAC | SDGs | ដៃគូអភិវឌ្ឍន៍របស់ សហភាពអឺរ៉ុប ឈានមុខ | ដៃគូអភិវឌ្ឍន៍របស់ សហភាពអឺរ៉ុប សកម្ម | ដៃគូអភិវឌ្ឍន៍ ផ្សេងៗ (នឹង ត្រូវបញ្ចប់) |
| | ការប្រែប្រួលអាកាសធាតុ និង DRR | ការការពារបរិស្ថានជាទូទៅ ( ៤១០) ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (៤៣០៦០) ការបង្ការ និងការត្រៀមបម្រុងចំពោះគ្រោះមហន្តរាយ (៧៤០) | ១៣.១, ១.៥, ២.៤, ១១b, ៩.៤ (បច្ចេកវិទ្យាបៃតង) ១១.៥ | FR (AFD) | CH, CZ, FR, DE, EU, EIB CZ | ADB, FAO, JAP, KOR, UNDP, UNESCO, UNIDO, UK, USA |
| | ថាមពលបៃតង និង ប្រសិទ្ធភាពថាមពល | ថាមពល (២៣០) | ៧.២ (ថាមពល) | FR | CZ, DE, EU | ADB, AUS, ចិន, JAP, KOR, NZ, USA |
| | ការបោសសម្អាតមីន | ពហុវិស័យផ្សេងទៀត (៤៣០) | ១៥ | CH | BE, DE, IE | KOR, JAP, UK, UNDP, USA |
| | **វិស័យអាទិភាពទី ៦ - ការគាំទ្រយ៉ាងសកម្ម និងប្រកបដោយការសម្របសម្រួលសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ដោយផ្តោតជាពិសេសលើ តែមិនកំណត់ត្រឹមតំបន់អង្គរទេ។** | | | | | |
| | បេតិកភណ្ឌវប្បធម៌ | ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គមផ្សេងទៀត (១៦០) | ១១.៤ (វប្បធម៌) | FR | BE, DE | ចិន, IAEA, KOR, UNESCO |